# ការសំម្ភាសន៍របស់ កៅ រស់ ហៅ កៅ លន់

កះ អ្នកសម្ភាសន៍គេមានរត្ន ពិសី ខះ អ្នកដែលត្រូវគេសម្ភាសន៍ កៅរស់ ហៅ កៅលន់

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ កៅ រស់ ហៅ កៅ លន់

ការសម្ភាសន៍ជីវប្រវត្តិរបស់លោកតា កៅ រស់ ហៅ កៅ លន់ហើយគាត់ជាកូនប្រុសមួយរូបដែរមានការដឹងគុណឪពុកម្ដាយហើយគាត់បានលះបង់ឪកាសការសិក្សាហើយដើម្បីទៅធ្វើការរកលុយចិញ្ចឹមម្ដាយហើយគាត់ធ្វើអីអត់កើតហើយគាត់មានការលំបាកជាច្រើននិងក្នុងជីវិតរបស់គាត់។ហើយគាត់បានឆ្លងកាត់នៅរឿងរ៉ាវជាច្រើននៅក្នុងជីវិតរបស់គាត់។សរបញ្ជាក់ថាគាត់ជាក្មេងប្រុសមួយរូបដែរបានលះបង់ភាពសប្បាយរបស់ដើម្បីរកលុយចិញ្ចឹមអ្នកម្ដាយរបស់គាត់និងប្អូនៗរបស់គាត់ដោយគាត់មិនថាអីមួយមាត់ហើយគាត់ជាមនុស្សមួយដែរតស៊ូនិងព្យាយាមនិងការងារ។ហើយគាត់ជាមនុស្សម្នាក់ដែរទៀងត្រង់និងមានការរសរាយរាក់ទាក់និងមានសុភាពរាបសាហើយគាត់មានការមេត្តានិងមានការអាណិតស្រឡាញ់អ្នកជិតខាង។

កះ ជាដំបូងខ្ញុំសូមជំរាបសួរកុងខ្ញុំបាទឈ្មោះរត្ន ពិសី ខ្ញុំសូមអនុញ្ញាតកុងធ្វើការសម្ភាសន៍អំពីជីវប្រវត្តិរបស់កុងដោយខ្ញុំធ្វើឡើងដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថា( ប៊ី វ៉ាយ យូរ ) ដែលមានទៅទីតាំងនៅសហរដ្ឋអាមេរិចដើម្បីថែរក្សាជីវប្រវត្តិរបស់កុងហើយដើម្បីថែរក្សាជីវប្រវត្តិជីដូនជីតារបស់កុងផងដែលដើម្បីទុកអោយកូនចៅជំនាន់ក្រោយគាត់បានស្គាល់ ហើយឲ្យគាត់បានដឹងថាអ្នកជំនាន់មុនគេមានការពិបាកអ្វីខ្លះនៅក្នុងជីវិតរបស់មនុស្សជំនាន់មុនមានការជួបឧបសគ្គអ្វីខ្លះអញ្ចឹងណាស់កុង។

ខះ បាទ!

កះ បាទ!ចឹងអញ្ចឹងកុងខ្ញុំធ្វើឡើងនៅថ្ងៃទី ១៦ ខែ ០៦ ឆ្នាំ ២០១៨ណាស់កុង?

ខះ បាទ!

កះ បាទ!ហើយអញ្ចឹងតើកុងមានឈ្មោះអ្វីដែកុង?

ខះ ខ្ញុំមានឈ្មោះ កៅ រស់។

កះ បាទ!ហើយអញ្ចឹងកុងមានឈ្មោះ កៅ រស់នឹងម៉ងកុង?

ខ៖ បាទ!ឈ្មោះ កៅ រស់។

ក៖ បាទ!ហើយអញ្ចឹងកុងមានឈ្មោះគេហៅក្រៅទេកុង?

ខ៖ ខ្ញុំមានគេហៅឈ្មោះខ្ញុំខាងក្រៅ។

ក៖ បាទ!ហើយអញ្ចឹងកុងមានឈ្មោះអ្វីដែរកុង?

ខ៖ គេហៅខ្ញុំថា កៅ លន់។

ក៖ បាទហើយអញ្ចឹងគេហៅកុងថា កៅ លន់?

ខ៖ បាទ!

ក៖ បាទ!ហើយអញ្ចឹងឈ្មោះនៅក្នុងសៀវភៅគ្រួសារឈ្មោះ កៅ រស់?

ខ៖ បាទ!អត់ទេនៅក្នុងបញ្ជីរកំណើតឈ្មោះ កៅ លន់។

ក៖ បាទ!ហើយអញ្ចឹងបញ្ជីរកំណើតឈ្មោះ កៅ លន់វិញបើឈ្មោះគេហៅខាងក្រៅឈ្មោះ កៅ រស់?

ខ៖ បាទ!

ក៖ បា៎ទ!ហើយអញ្ចឹងកុងសព្វថ្ងៃនឹងតើកុងមានអាយុប៉ុន្មានកុង?

ខ៖ ខ្ញុំសព្វថ្ងៃនឹងខ្ញុំមានអាយុ ៨៥ឆ្នាំហើយ។

ក៖
បាទ!ហើយអញ្ចឹងកុងមានអាយុ៨៥ឆ្នាំហើយ។បាទ!ហើយអញ្ចឹងកុងមានចាំថ្ងៃខែឆ្នាំកំណើររបស់កុងទេកុងដូចឆ្នាំបារាំងកុងមានចាំទេកុង?

ខ៖ បាទ! ខ្ញុំភ្លេចហើយនឹងហើយខ្ញុំដឹងថាខ្ញុំឆ្នាំ ចនឹង។

ក៖ បាទ!ហើយអញ្ចឹងកុងចាំថាឆ្នាំខ្មែរយើងឆ្នាំចកុង?

ខ៖ បាទ!ខ្ញុំឆ្នាំចកើតខែនាគ។

ក៖ បាទ!ហើយអញ្ចឹងកុងកើតនៅខែ នាគ ដូចជាខែ៣មែនកុង?

ខ៖ បាទ!ខ្ញុំកើតនៅខែ នាគនិងត្រូវនិងខែ កណ្ដឹកនិង។

កៈ បាទ!ហើយអញ្ចឹងកុងប្រហែលជាខែ ៤ទៅខែ ៥នឹងហើយកុង។

ខៈ ខ្ញុំអត់ដឹងថាខែណាមុនទេជួយមើលខ្ញុំតិចហើយខ្ញុំអត់ដឹងថាខែ នាគមុនខែ កណ្ដុរ ឬខែកណ្ដុរមុនខែ នាគទេប្រហែលខែកណ្ដុរមុនខែនាគ។

កៈ បាទ!

ខៈ កណ្ដុរនាគនឹងហើយ។

កៈ បាទ!ហើយអញ្ចឹងកុងមានចាំទីកន្លែងកំណើតរបស់កុងដោយផ្ទាល់ខ្លួនរបស់កុងទេកុង?

ខៈ បាទ! ស្រុកកំណើតខ្ញុំនៅនឹង។

កៈ
បាទ!ហើយអញ្ចឹងស្រុកកំណើតរបស់កុងនៅនឹងកុង។បាទ!ហើយអញ្ចឹងកុងជាអ្នកកោះឧកញ៉ាតីនឹងម៉ងកុង?

ខៈ បាទ!ខ្ញុំអ្នកនៅកោះឧកញ៉ាតីនឹងម៉ង។

កៈ បាទ!ហើយអញ្ចឹងកុងនៅនិងគេហៅភូមិអ្វីដែរកុង?

ខៈ បាទ!នៅនិងគេហៅភូមិ ខ្ពប ឃុំ កោះឧកញ៉ាតី។

កៈ បាទ!ហើយអញ្ចឹងនៅនិងគេហៅភូមិ ខ្ពបកុង?

ខៈ បាទ!

កៈ បាទ!ហើយអញ្ចឹងនៅនឹងគេហៅភូមិ ខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលកុង?

ខៈ បាទ!

កៈ បាទ!ហើយអញ្ចឹងកុង មានបងប្អូនបង្កើតប៉ុន្មាននាក់ដែរកុង?

ខៈ ខ្ញុំមានបងប្អូនបង្កើតមាន៤នាក់។

កៈ បាទ!ហើយអញ្ចឹងកុងមានបងប្អូនបង្កើត មាន៤នាក់កុង?

ខៈ បាទ!

កៈ បាទ!ហើយអញ្ចឹងកុងជាកូនទីប៉ុន្មានដែរកុង?

ខ៖ ខ្ញុំជាកូនទី៣។

ក៖ បាទ!ហើយអញ្ចឹងកុងជាកូនទី៣កុង?

ខ៖ បាទ!

ក៖ បាទ!ហើយអញ្ចឹងកុងជាកូនបន្ទាប់ពីកូន៧?

ខ៖ បាទ!មើរបងប្អូនខ្ញុំ៥នាក់ណាស់។

ក៖ បាទ!ហើយអញ្ចឹងបងប្អូនកុងមាន៥នាក់វិញមិនមែន៨នាក់ទេកុង?

ខ៖ បាទ!ខ្ញុំមានបងប្អូនបង្កើត៥នាក់។

ក៖ បាទ!ហើយអញ្ចឹងកុងជាកូនទី៣?

ខ៖ បាទ!ខ្ញុំជាកូនទី៣។

ក៖
បាទ!ហើយអញ្ចឹងកុងមានចាំឈ្មោះបងៗរបស់កុងហើយនិងប្អូនៗរបស់កុងទេហើយពួកគាត់មានឈ្មោះអ្វីខ្លះកុង?បងគេបង្អស់មានឈ្មោះអ្វីដែរកុង?

ខ៖ បងគេបង្អស់មានឈ្មោះថា បង ម៉ន ។

ក៖ បាទ!ហើយបងគេបង្អស់មានឈ្មោះ ម៉ន ?ហើយអញ្ចឹងបងទីពីរមានឈ្មោះអ្វីដែរកុង?

ខ៖ បាទ!ហើយបងទីពីរមានឈ្មោះថា បង គួក។

ក៖
បាទ!ហើយអញ្ចឹងបងទីពីរមានឈ្មោះថាបងគួក?ហើយអញ្ចឹងប្អូនបន្ទាប់ពីកុងមានឈ្មោះអ្វីដែរកុង?

ខ៖ ប្អូនបន្ទាប់ខ្ញុំមែន?

ក៖ បាទ!

ខ៖ ហើយប្អូនបន្ទាប់ពីរខ្ញុំមានឈ្មោះថា ពួត ។

ក៖ បាទ!ហើយអញ្ចឹងប្អូនបន្ទាប់ពីកុងមានឈ្មោះ ពួត?
ហើយអញ្ចឹងប្អូនទី៤មានឈ្មោះអ្វីដែរកុង?

ខ៖ បាទ!ហើយប្អូនទី៤និងមានឈ្មោះ អាគាំង។

ក៖ បាទ!ហើយអញ្ជឹងប្អូនទី៤របស់កុងមានឈ្មោះ អាគាំង?

ខ៖ បាទ!

ក៖
បាទ!ហើយអញ្ជឹងកុងបងប្អូនរបស់កុងនិងគាត់មានប្រជន្មារាល់ថ្ងៃនិងឬក៏គាត់បានចែកឋានទៅហើយកុង?

ខ៖ បាទ!ហើយខ្ញុំមានបងពីរនាក់គាត់បានចែកឋានហើយគាត់មានឈ្មោះបងគួក និងបងម៉ន គាត់ពីរនាក់និងគាត់ចែកឋានហើយ។

ក៖ បាទ!

ខ៖ ហើយឥឡូវនិងបងខ្ញុំមួយទៀតនិងបង
ពួតនិងគាត់រៀងបឹសៗហើយគាត់ឈឺយូរហើយដែរនិងហើយក្រៅពីនិងគាត់គេនៅរស់ទេ។

ក៖ បាទ!ហើយអញ្ជឹងកុងនៅសល់ប្អូនពៅនិងកុង?

ខ៖ បាទ!

ក៖
បាទ!ហើយអញ្ជឹងកុងមានចាំថាបងៗរបស់កុងនិងគាត់បានស្លាប់នៅក្នុងជំនាន់ប៉ុលពតឬក៏គាត់ពេលដែរបែកពីប៉ុលពតវិញកុង?
ខ៖ បាទ!ហើយគាត់ស្លាប់ពីបែកប៉ុលពតវិញទេពេលគាត់ស្លាប់និងបែកហើយនិង។

ក៖ បាទ!ហើយអញ្ជឹងបងរបស់កុងគាត់ស្លាប់ពេលចប់ប៉ុលពតហើយកុងណោះកុង?

ខ៖ បាទ!

ក៖
បាទ!ហើយអញ្ជឹងគាត់ស្លាប់ដោយជម្ងឺចាស់ស្លាប់ហើយគាត់មិនគេយកគាត់ទៅសម្លាប់ទេកុងណោះ?
ខ៖ បាទ!គាត់មានជម្ងឺចាស់ស្លាប់និងហើយគាត់អត់មានជម្ងឺអីផ្សេងទេ។

ក៖
បាទ!ហើយអញ្ជឹងកុងមានចាំសាច់រឿងកុងជាមួយបងប្អូនរបស់កុងទេហើយដូចធ្លាប់ធ្វើអីជាមួយគ្នាអញ្ជឹងកុងហើយមានការលំបាកជាមួយកាលពីជំនាន់ប៉ុលពតកុងមានចាំទេកុង?

ខ៖
បាទ!កាលពីជំនាន់ប៉ុលពតខ្ញុំអត់មានបានទៅណាទេបងប្អូនខ្ញុំគាត់នៅនិងទាំងអស់គ្នានិងអត់មានទៅណាទេ។

ក៖ អរចឹងកុងនៅនឹងទាំងអស់គ្នាអត់មានរត់ទៅណាទេ?

ខ៖ បាទ!

ក៖ បាទ!ចឹងគុងមានចាំសាច់រឿងដូចជាធ្លាប់ទៅណាជាមួយគ្នាទេគុង?

ខ៖ មានតាកាលនឹងទៅរកស៊ីចិញ្ចឹមឪពុកម្តាយតាពិននឹងរឿងរ៉ាវជាមួយបងប្អូននឹង។

ក៖ អរបាទ!ចឹងពេលនឹងតើគុងរកស៊ីអ្វីដែលគុង?

ខ៖ មុតគ្រោះដល់ពេលអត់ពីឪពុកទៅណាស់។

ក៖ បាទ!

ខ៖ ជ្រមុតគ្រោះជាមួយបងខ្ញុំនឹងឈ្មោះបង ម៉ន
ជ្រមុតគ្រោះនៅកោះដាច់នឹងបានទៅរកគ្រោះរាល់ឆ្នាំចឹងទៅដល់ពេលប្តូកគាត់មានប្រពន្ធអស់ទៅក៏បងម៉ននឹងគាត់មានប្រពន្ធបងគួកក៏មានប្រពន្ធបើខ្ញុំវិញក៏មានប្រពន្ធកាលនឹងប្អូនវាទៅធ្វើការនៅគីឡូលេខ៦នោះហើយកាលវាធ្វើនឹងនៅគីឡូលេខ៦ខ្ញុំក៏លែងប្រពន្ធរៀបចំមកកើបគ្រោះជាមួយអាប្អូននឹងវាដឹងថាខ្ញុំទំនេរហើយ។

ក៖ បាទ!គុង?

ខ៖ វាធ្វើការនៅចំការដេរណាស់។

ក៖ បាទ!គុង?

ខ៖
បាទ!គេអោយវាទៅរកមនុស្សទៅយៀមនៅកំពងផែនៅគីឡូលេខ៦នឹងនៅកំពងផែនឹងនៅចំការដេរនឹងយៀមទៅបានប៉ុន្មានវាអោយខ្ញុំទៅណាទេខ្ញុំចង់វង្វេងហើយ។

ក៖ បាទ!អត់អីទេគុងបើគុងភ្លេចមិនអីទេគុងនិយាយអ្វីដែលគុងចាំទៅបានហើយ?

ខ៖
បាទ!ខ្ញុំទៅយៀមនៅឯងចំការដេរនឹងងាចោនឹងវាមកលួតភ្លេងនៅក្នុងកំពងផែខ្ញុំនឹងណាស់
។

កៈ បាទ!អរគាត់មកលេងភ្លេងគុង?

ខៈ បាទ!ខ្ញុំនៅយៀមនៅកន្លែងលេងភ្លេងនឹង។

កៈ បាទ!គុងអរគេអោយគុងនៅយៀមនៅកន្លែងភ្លេង?

ខៈ បាទ!ដល់ពេលខ្ញុំយៀមទៅចោលនឹងវាមកលួតអាភ្លេងនឹងណាស់។

កៈ បាទ!

ខៈ ពួកកម្ពុជាក្រោមអានឹង។

កៈ អរពួកកម្ពុជាក្រោម?

ខៈ
បាទ!ដល់ពេលវាមកលួតខ្ញុំចាប់បានដល់ពេលទៅខ្ញុំវៃវាក្បែចង់ងាប់នឹងដែលកុបទៅជាប់ជើងមិនអោយខុសទេ។

កៈ បាទ!គុងពេលនឹងគុងខ្លាំងដែលនឹងណាស់?

ខៈ បាទ!ពេលនឹងកុបពាំងក្ដុបៗដែលនឹងណាស់មិនអោយខុសទេ។

កៈ បាទ!ពេលនឹងចោលប៉ុន្មាននាក់ដែលគុង?

ខៈ គ្នាវាមានពីនាក់តែខ្ញុំចាប់បានតាមួយនាក់ទេ។

កៈ បាទ!ចឹងគុងតាម្នាក់ឯងទេតែគ្នាគេមានពីរនាក់?

ខៈ អត់ទេគ្នាខ្ញុំមានបីនាក់ដែល។

កៈ បាទ!អរចឹងគ្នាគុងមានបីនាក់ដែល?

ខៈ បាទ!អាពីនាក់នឹងដួលទាំងអស់។

កៈ បាទ!ដួលទាំងអស់នៅតាគុងម្នាក់ឯង?

ខៈ បាទ!នៅតាខ្ញុំម្នាក់ឯងខ្ញុំវៃបានវារត់ទៅបុកខ្សែភ្នើងគេចងនៅបង្គោលភ្នើងនឹងណាស់។

កៈ បាទ!

ខ៖
ខ្ញុំកុបវាត្រូវបីដងហើយខ្ញុំវៃវាបានបីដងហើយមកបុកខ្សែភ្លើងនឹងផុកៗដល់ហើយខ្ញុំដាក់វាធឹសៗទៀតវាទំនាក់ដៃអោយខ្ញុំចាប់ម៉ងពួកនៅនឹងវាកម្ពុជាក្រោមដែលណាស់ខ្ញុំមិនដឹងថាវាត្រូវគ្នាក៏អត់ទេ។

ក៖ បាទ!

ខ៖
ខ្ញុំថាអោយយកក្រម៉ាយកមកចងវាសួរអ្នកណាក៏អត់ៗៗសួរទៅខ្ញុំឃើញជៀងចេកពងមាន់យើងនឹងយកមកចងក្តោបវាទៅ។

ក៖ បាទ!ចងក្តោបគួតក្រោយទៅ?

ខ៖
បាទ!ដល់ពេលហើយមូលដាច់ៗដល់ហើយយកវាទៅកន្លែងប៉ុសគុងធ្នាទៅដល់នឹងប៉ុសគុមធ្នាទៅដល់គេសួរខ្ញុំថាហៅអ្នកវៃនឹងទៅសួរដល់ពេលសួលសួតទៅបានហៅខ្ញុំចូលទៅខ្ញុំក៏ចូលទៅគុងធ្នានឹងត្រូវជាមួយពួកវាទៀតនឹងបន្ទោះអោយខ្ញុំម៉ងថាអូនឯងវៃគេនឹងខុសហើយបើខ្ញុំមិនវៃគេដឹងថាខ្ញុំចាប់វាអត់បានទេនេះខ្ញុំឆ្លើយត្រូវហើយបានខ្ញុំចាប់បាននឹងណាស់។

ក៖ បាទ!បើកុងវៃខុសកុងមិចចាប់ចោលបាន?

ខ៖
បាទ!មិចចាប់បានមែនតាខ្ញុំខុសខ្ញុំនិយាយថាចោលវាលួតឡានដែកគុនដែកគុនអោយឡានវាឬមួយដែកគុនយកឡានពីវាវិញគាត់ថាអេតាចាប់បានហើយត្រូវតែយកឡានមកវិញបានចឹងខ្ញុំដែលនឹងដូចតា

គ្នានឹង។

ក៖ បាទ!ពេលនឹងកុងខ្លាំងដែលនឹង?

ខ៖ បាទ!ពេលនឹងខ្ញុំនៅពេញកម្លាំង។

ក៖
បាទ!ចឹងតើកុងនឹងបងប្អូនកុងតើមានចូលចិត្តធ្វើអ្វីជាមួយគ្នាទេកុងបងប្អូនកុងនឹងណាស់ដូចជាដើរលេងជាមួយគ្នាទៅណាមកណាជាមួយគ្នាចឹងណាស់កុង?

ខ៖ មានខ្ញុំធ្លាប់ដើរលេងជាមួយគ្នាមាន។

ក៖ អរមានកុង?

ខ៖
បាទ!ធ្វើការជាមួយគ្នាអីនឹងមានរកគ្រោះក៏មានជាមួយបងៗនឹងបងពីរខ្ញុំរកគ្រោះជាមួយបងទីពីរឈប់រកគ្រោះទៅទិញអំពៅគេយកមកលក់នឹងពីដើមមកណាស់។

ក៖ បាទ!កុង?

ខ៖ បាទ!លក់អំពៅទិញអំពៅយកមកលក់ទៅដល់ព្រៃកតាម៉ាក់អីចឹងទៅ។

ក៖ អរកុងទៅលក់បានឆ្ងាយទៀតណាស់?

ខ៖ បាទ!បើកក្បោងទៅលក់មួយថ្ងៃទល់តែល្ងាចដែលនឹង។

ក៖ បាទ!

ខ៖ បើមានខ្យលម៉ោង២ ៤អីទៅដល់ហើយ។

ក៖
បាទ!ចឹងក្រុមគ្រួសារកុងទាំងអស់គ្នានឹងពួកគាត់ជាអ្នករស់នៅក្នុងកោះនឹងទាំងអស់គ្នានឹងម៉ងកុង?

ខ៖ បាទ!រស់នៅក្នុងកោះនឹងម៉ង។

ក៖ បាទ!ចឹងតើកុងមាននៅចាំឈ្មោះឪពុកម្ដាយរបស់កុងទេ?

ខ៖ ខ្ញុំចាំតា។

ក៖ បាទ!ចឹងលោកឪពុករបស់កុងតើគាត់មានឈ្មោះអ្វីដែលកុង?

ខ៖ លោកឪពុកខ្ញុំគាត់មានឈ្មោះថា កៅ ខ្យង។

ក៖ អរលោកឪពុករបស់កុងមានឈ្មោះថា កៅ
ខ្យងបាទចឹងអ្នកម្ដាយរបស់កុងតើគាត់មានឈ្មោះអ្វីដែលកុង?

ខ៖ អ្នកម្ដាយខ្ញុំគាត់មានឈ្មោះថា យាយ វ៉ាន់ មក់ វ៉ាន់នឹងឈ្មោះពេញ។

ក៖ អរបាទ!ចឹងអ្នកម្ដាយរបស់កុងមានឈ្មោះថា មក់
វ៉ាន់បាទចឹងតើកុងមាននៅចាំថាតើគាត់មានអាយុប៉ុន្មានហើយមុននឹងគាត់ចែកឋានទៅកុង
?

ខ៖ អរខ្ញុំចង់ភ្លេចបាត់ហើយ។

កៈ បាទ!មិនអីទេបើកុងផ្លេចនោះ?

ខៈ បាទ!គាត់មានអាយុច្រើនដែលហើយ។

កៈ អរគាត់មានអាយុច្រើនដែលហើយ?

ខៈ បាទ!

កៈ បាទ!ចឹងតើកុងមាននៅចាំឆ្នាំខ្មែរឪពុកម្តាយកុងទេដូចជា ជូត ឆ្លូវ ខាល ថោះអីចឹងណាស់កុង?

ខៈ អរខ្ញុំចង់ផ្លេចអស់ហើយប្អូនអើយយូរហើយ។

កៈ បាទ!អត់អីទេកុង?

ខៈ បាទ!

កៈ បាទ!ចឹងឪពុកម្តាយរបស់កុងពួកគាត់ជាអ្នកនៅកោះឧញ្ញាតីនឹងម៉ង?

ខៈ បាទ!គាត់ជាអ្នកនៅកោះឧញ្ញាតីនឹង។

កៈ បាទ!ចឹងស្រុកកំណើតរបស់គាត់ក៏នៅនឹងដែល?

ខៈ បាទ!នៅនឹងទាំងអស់គ្នានឹង។

កៈ បាទ!ចឹងឪពុកហើយនឹងអ្នកម្តាយរបស់កុងពួកគាត់ជាអ្នកនៅក្នុងភូមិជាមួយគ្នា?

ខៈ បាទ!នៅនឹងនៅជាប់គ្នានឹង។

កៈ បាទ!ដល់ពេលចឹងគាត់ឃើញគ្នាទៅក៏ស្រលាញ់គ្នាទៅកុង?

ខៈ ពេលនឹងឪពុកម្តាយគាត់ចាអ្នកផ្សំផ្គំមអោយទេ។

កៈ អរបាទ!ពេលនឹងឪពុកម្តាយគាត់ជាអ្នកផ្សំផ្គំមអោយទៅ?

ខៈ ដល់ពេលទៅដណ្តឹងម្តាយខ្ញុំនឹងជីតាខ្ញុំនឹងគាត់កំពងធ្វើផ្ទះដល់ពេលចឹងទៅតាខ្ញុំគាត់និយាយថាអ្នកឯងជួយធ្វើផ្ទះខ្ញុំសិនទៅចាំរៀបការ។

កៈ
បាទ!ចឹងពេលនឹងលោកឪពុករបស់កុងក៏ជួយធ្វើផ្ទះអោយជីតាខាងម្ដាយកុងទៅមួយថ្ងៃទល់តែល្ងាចទៅ?

ខៈ បាទ!គាត់ជួយធ្វើផ្ទះនឹងរហូតដល់តែហើយផ្ទះនឹងណាស់។

កៈ បាទ!ដើម្បីចង់បានម្ដាយរបស់កុងអញ្ជឹងកុង?

ខៈ បាទ!គាត់ជួយធ្វើផ្ទះនឹងទល់តែរួតនឹងបានផ្ទះនឹងរៀបការទៅ។

កៈ
បាទ!ចឹងកុងតើកុងមាននៅចាំថាតើលោកឪពុកហើយនឹងអ្នកម្ដាយរបស់កុងតើពួកគាត់ប្រកបមុខរបរអ្វីខ្លះដើម្បីចិញ្ចឹមកុងហើយនឹងបងប្អូនកុងណាស់តើគាត់ប្រកបមុខរបរអ្វីដែលកុង?

ខៈ គាត់រកស៊ីតាមទូកតាមកាណូតចឹងដែល។

កៈ បាទ!អរចឹងគាត់ទៅតាមទូកតាមកាណូតដែលកុង?

ខៈ បាទ!រកស៊ីគាត់មានទូកចឹងណាស់។

កៈ បាទ!អរចឹងគាត់មានទូកផ្ទាល់ខ្លួន?

ខៈ បាទ!គាត់មានទូកផ្ទាល់ខ្លួនគាត់នឹង។

កៈ បាទ!ចឹងលោកឪពុករបស់កុងគាត់ជាអ្នកធ្វូរធារដែលកុង?

ខៈ បាទ!គាត់ជាអ្នកដើររកស៊ីទៅដល់កំពង់ឆ្នាំងទៅដល់អីណាទេឆ្ងាយៗ។

កៈ បាទ!ចឹងគេហៅថាអ្នកជំនួនណាស់កុង?

ខៈ
បាទ!កាលជំនាន់នឹងគាត់ជាអ្នកជំនួនកាលនឹងគាត់ទិញឪឡឹកទិញត្រឡាតល្ពៅអង្ករយកមកលក់នៅស្រុកយើងចឹងទៅ។

កៈ បាទ!អរចឹងគាត់ទៅទិញពីអ្នកនៅខេត្តគេផ្សេងទៅគាត់យកមកលក់នៅស្រុកយើទៅ?

ខៈ បាទ!នឹងហើយ។

កៈ បាទ!នឹងគេហៅថាអ្នកជំនួញហើយ?

ខ៖ បាទ!បើខ្ញុំវិញដើរទូកជាមួយគាត់ទៅ។

ក៖ បាទ!អរចឹងកុងដើរទូកជាមួយលោកឪពុកទៅ?

ខ៖ បាទ!ជ្វារទូកទៅជាមួយគាត់ទៅ។

ក៖ បាទ!ចឹងអ្នកម្ដាយរបស់កុងគាត់ជាមេផ្ទះ?

ខ៖ បាទ!អ្នកម្ដាយរបស់ខ្ញុំគាត់ជាមេផ្ទះ។

ក៖ បាទ!គាត់អត់មានប្រកបមុខរបរអ្វីទេគាត់ដឹងថាគាត់នៅផ្ទះធ្វើម្ហូបមើកូនចឹងទៅ?

ខ៖ បាទ!គាត់នៅមើកូនចៅនៅផ្ទះចឹងទៅ។

ក៖ បាទ!ចឹងគាត់មានចេះត្បាញទេកុង?

ខ៖ មានដែលពីដើមមកមានដែរនិងពីដើមមក។

ក៖ អរបាទ!ចឹងអ្នកម្ដាយរបស់កុងគាត់ចេះត្បាញដែរ?

ខ៖ បាទ!នឹងហើយ។

ក៖ បាទ!គាត់ត្បាញក្រម៉ាលត្បាញហូរអីចឹងទៅកុង?

ខ៖ បាទ!គាត់ត្បាញក្រម៉ាលមិនដឹងអីទេពីដើមមក។

ក៖
បាទ!ចឹងចំពោះកុងវិញតើកុងគិតបែកណាចំពោះលោកឪពុករបស់កុងតើគាត់ជាមនុស្សកាតឬមួយក៏គាត់ស្លូតកុង?

ខ៖ ឪពុកខ្ញុំគាត់ស្លូតណាស់។

ក៖ បាទ!គាត់ស្លូតកុង?

ខ៖ បាទ!ស្លូតណាស់។

ក៖ បាទ!ចឹងតើគាត់មានដែលធ្លាប់វៃកុងទេ?

ខ៖ គាត់មិនដែលវៃខ្ញុំទេបើគាត់វៃក៏គាត់វៃមិនប៉ុន្មានដែលនឹងបន្តិចបន្តួតដែរនឹង។

ក៖ អរបាទ!គាត់វៃដែលតែបន្តិចបន្តួតនៅពេលដែលកុងខូតរឹងអីទៅ?

ខ៖ បាទ!យើងខូតរឹងជាមួយគាត់ចឹងទៅគាត់វៃខ្លះៗទៅ។

ក៖ បាទ!តែគាត់ស្រលាញ់កូន?

ខ៖ បាទ!គាត់មិនដែលអត់ស្រលាញ់កូនចៅទេគាត់ស្រលាញ់កូនចៅណាស់។

ក៖ បាទ! ហើយអញ្ចឹងអ្នកម្តាយក៏គាត់អញ្ចឹងដែរកុងណោះ។

ខ៖ បាទ! ហើយគាត់ស្រឡាញ់កូនចៅណាស់កាលនៅជាមួយគាត់និងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយគាត់នៅជុំគ្នាទាំងអស់និងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយខ្ញុំនិងកំសត់កំរដែរហើយអត់ដឹងធ្វើមិច។

ក៖ បាទ! ហើយអញ្ចឹងកុងកំសត់កំរដែរណោះកុង។

ខ៖ បាទ! ហើយគាត់បានកូនចៅជួយប្រឹងប្រែងទៅហើយគាត់ក៏បានធូរធាទៅណាស់។

ក៖ បាទ!
ហើយអញ្ចឹងគាត់មានកូនជួយការងារគាត់ហើយជួយរកលុយឲ្យគាត់ទៅហើយគាត់បានធូរធាទៅកុង។

ខ៖ បាទ! ហើយកាលនិងឪពុកខ្ញុំស្លាប់និងខ្ញុំទៅជ្រមុះគ្រួសជាមួយបងខ្ញុំ។

ក៖ បាទ!

ខ៖
ហើយខ្ញុំជ្រមុះគ្រួសតាំងពីតូចមកហើយខ្ញុំជួយចិញ្ចឹមម្តាយមករហូតនិងណាស់ហើយគាត់បានធូរដៃជើងគាត់ខ្លះទៅណាស់។

ក៖ បាទ!
ហើយអញ្ចឹងកុងកាលនិងឪពុកម្តាយរបស់កុងគាត់ស្លាប់ដោយសារមូលហេតុអីដែរកុង?ហើយឬគាត់មានជម្ងឺប្រចាំខ្លួនមែនកុង?

ខ៖ បាទ!ជម្ងឺនិងអញ្ញេកទេមិនអីទេណាស់។

ក៖ បាទ! កុងហើយមានជម្ងឺមហារីកមែនកុង។

ខ៖ បាទ!អត់ទេហើយគេនោះខូតនិងគ្នាហើយតែមេបាងនេះ។

ក៖ បាទ!

ខ៖ ហើយកូនចៅគេនោះខូចនិងគ្នាមេបានៅនេះហើយខ្សែស្រឡាយជាមួយនិងណាស់។

ក៖ បាទ!

ខ៖ ហើយមេបាកាចគាត់។

ក៖ បាទ! ហើយអញ្ចឹងមេបាកាចគាត់កុង។

ខ៖ បាទ! នឹងហើយប៉ុន្មានដងហើយនិងមួយដងប្រាំមួយប្រាំពីរថ្ងៃហើយនិង។

ក៖ បាទ! ហើយអញ្ចឹងមេបាកាចប្រាំមួយប្រាំពីរថ្ងៃដែរកុង?

ខ៖ បាទ! ហើយបានគាត់ស្លាប់និង។

ក៖ បាទ! ហើយអញ្ចឹងគាត់អត់មានជម្ងឺអីទេ។

ខ៖ អត់ទេ។ហើយមានអីទេហើយបើជម្ងឺគាត់គឺអាណុងម៉ងនិង។

ក៖ បាទ!

ខ៖ ហើយអញ្ចឹងគេហៅមេបានិងណាស់។

ក៖ បាទ! ហើយអញ្ចឹងគេហៅខុសមេបាហើយនិងខុសចាស់ទុំ។

ខ៖ បាទ! ហើយនិងគេថាខុសចាស់ទុំហើយពេលដែរគាត់បានស្លាប់ទៅណាស់។

ក៖ បាទ!

ខ៖ ហើយមានអីរកស៊ីមានតែមុចគ្រួសនិងហើយ។

ក៖ បាទ!

ខ៖ បាទ! ខ្ញុំមុចគ្រួសជាមួយបងប្អូនទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងមុចគ្រួសជួយចិញ្ចឹមអ្នកម្ដាយ។

ខ៖ បាទ! ហើយខ្ញុំជួយគាត់និងហើយនិងខ្ញុំរកពីរនាក់គ្នាទៅ។

ក៖ បាទ! ហើយអញ្ចឹងកុងមានខ្សែជីវិតជាមួយពួកគាត់ច្រើនណាស់កុងណោះ។

ខ៖ បាទ! មានច្រើនដែរនិង។

ក៖ បាទ!

ខ៖ ខ្ញុំកំសត់កំរណាស់ប្អូនអើយហើយហេតុតែយើងក្រណាស់។

ក៖ បាទ!

ខ៖ ហើយយើងចិញ្ចឹមម្ដាយទៅហើយឪពុកយើងនិងគាត់បានស្លាប់ហើយនិង។

ក៖ បាទ!

ខ៖ ហើយយើងមានអីអាងអីទៀត។

ក៖ បាទ! ហើយណាមួយបងប្អូនកុងសុទ្ធតែប្រុសៗទៀត។

ខ៖ បាទ! ហើយខ្ញុំមានបងប្អូននិងប្រុសៗទៀត។

ក៖ បាទ!

ខ៖ បាទ! មានអីទេមានតែរកស៊ីមុចគ្រួសទៅណាស់។

ក៖ បាទ!

ខ៖
ហើយខ្ញុំនិងបងប្រុសខ្ញុំហើយនិងតមករហូតប្អូនប្រុសខ្ញុំនិងរហូតមកហើយដល់ចាស់ៗនិង
ទៅណាស់។

ក៖ បាទ!

ខ៖ ហើយកាលពីមុនជំនាន់អាពតនិងណាស់។

ក៖ បាទ!ហើយអញ្ចឹងកុងបើនិយាយពីបងប្អូនរបស់កុងអត់មានស្រីទេកុង?

ខ៖ អត់មានទេ។

ក៖ បាទ! ហើយអញ្ចឹងកុងអត់មានប្អូនស្រីទេកុង?

ខ៖ បាទ!

កៈ បាទ! ហើយអញ្ចឹងកុងមានបងប្អូនប្រុសទាំងអស់ម៉ងកុង?

ខៈ បាទ! ខ្ញុំមានបងប្អូនប្រុសទាំងអស់ម៉ងនិងណាស់។

កៈ បាទ! ហើយអញ្ចឹងកុងស្រឡាញប្អូនស្រីអត់កុង?

ខៈ បាទ!ហើយខ្ញុំបានប្រពន្ធមកហើយខ្ញុំបានកូនស្រីនិងខ្ញុំស្រឡាញ់ណាស់។

កៈ បាទ! ហើយអញ្ចឹងបានកុងស្រឡាញ់កូនស្រីព្រោះអីកុងអត់មានប្អូនស្រីផងនិង។

ខៈ បាទ! ហើយដល់ពេលវាស្លាប់ទៅខ្ញុំលង់លូចតែម្តង។

កៈ បាទ!

ខៈ ហើយខ្ញុំបានកូនស្រីៗនិងវាដឹងហើយបានខ្ញុំធូរ។

កៈ បាទ!

ខៈ ហើយបានខ្ញុំធូរអត់បារម្ភ។

កៈ បាទ!

ខៈ ហើយខ្ញុំបានកូនស្រីច្បងនិងណាស់។

កៈ បាទ! កុង។

ខៈ បាទ !ហើយកូនស្រីខ្ញុំនិងវាចេះណាស់លោកអើយកូនស្រីមួយនិងណាស់។

កៈ បាទ!
ហើយអញ្ចឹងកុងមានចាំសាច់រឿងអីជាមួយឪពុកម្តាយរបស់កុងទេកុងហើយដូចកុងបាន ប្រាប់ខ្ញុំថាកុងបានទៅជាមួយលោកឪពុកទៅទិញរបស់អីពីស្រុកគេយកមកលក់កុងមានចាំ ទេកុង?

ខៈ
បាទ!អត់មានអីទេណាហើយពេលខ្ញុំបានទៅជាមួយគាត់និងខ្ញុំបានទៅត្រឹមកំពង់ឆ្នាំងនិង ណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំទិញពីណុងមកហើយកាលនិងទិញឥឡឹកអីមក។

កៈ បាទ! ហើយអញ្ចឹងកុងកាលពីជំនាន់និងជិៈទូកទៅកុង។

ខៈ បាទ! ជិៈទូកទៅកាលនិងមានអីចូវទូកទៅណាស់។

កៈ បាទ!ហើយអញ្ចឹងកាលនិងចូវទូកទៅកុង។

ខៈ បាទ! ហើយចូវទូកទៅបួនប្រាំថ្ងៃបានទៅដល់។

កៈ បាទ! ហើយអញ្ចឹងកុងចូវបួនប្រាំថ្ងៃបានទៅដល់កំពង់ឆ្នាំង។

ខៈ បាទ!

កៈ ហើយកុងមានបានចូលទៅសៀមរាបទេកុង។

ខៈ បាទ! អត់បានទៅកាលនិងខ្ញុំអត់បានចូលទេ។

កៈ បាទ! ហើយកុងអត់ចូលទៅដល់និងហើយបានទៅតែកំពង់ឆ្នាំងកុង។

ខៈ បាទ! ហើយកាលនិងខ្ញុំបានទៅត្រឹមស្រុក ឈូងទេណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំអត់បានទៅទៀតទេ។

កៈ បាទ!

ខៈ ហើយឲ្យខ្ញុំទៅដល់សៀមរាបអីអត់ទេ។

កៈ បាទ!

ខៈ ហើយបើខ្ញុំទៅណាស់ជីវិតខ្ញុំវេទនាណាស់ប្អូនអើយ។

កៈ បាទ!

ខៈ ហើយកាលនិងចូវទូកទៅហើយចូវទូកមក។

កៈ បាទ!

ខៈ ហើយពេលណាមានកាណូតហើយបានស្រដោងកាណូតទៅណាស់។

កៈ បាទ! ហើយកុងហាត់ពេកស្រដោងកាណូតទៅទៅ។

ខ៖ បាទ! ស្រដោងកាណូតទៅហើយបានទៅអង្គុងវែងទៅ។

ក៖ បាទ! ហើយអញ្ចឹងកាលនិងកុងសុំគេស្រដោងកុង។

ខ៖ បាទ! អត់ទេកាលនិងខ្ញុំជួលគេនិង។

ក៖ បាទ! ហើយអញ្ចឹងកុងជួលគេកុងព្រោះអីហាត់ពេកជួលគេម៉ងទៅ។

ខ៖ បាទ! ហាត់ពេកជួលគេខ្លះហើយយើងចូវខ្លះអីទៅណា។

ក៖ បាទ! ហើយកាលនិងគេយកប៉ុន្មានដែរកុង។

ខ៖ បាទ! កាលនិងគេបួនដប់រៀលអីទៅ។

ក៖ បាទ! ហើយអញ្ចឹងកាលនិងគេយកបួនដប់រៀលកុង។

ខ៖ បាទ!

ក៖ បាទ! ហើយលុយកាលពីជំនាន់ថ្លៃកុង។

ខ៖ បាទ! កាលពីជំនាន់លុយថ្លៃណាស់បួនដប់រៀលដប់ប្រាំរៀលទៅណាស់។

ក៖ បាទ!

ខ៖ ហើយទូកមួយនិងស្រដោងអញ្ចឹងទៅ។

ក៖ បាទ! ហើយអញ្ចឹងស្រដោងពីខេត្ត កណ្តាលនិងរហូតដល់ខេត្ត កំពង់ឆ្នាំងទៅកុង។

ខ៖ បាទ! គេស្រដោងរហូតដល់ខេត្ត កំពង់ឆ្នាំងទៅណាស់។

ក៖ បាទ!

ខ៖ ហើយទៅទិញឥឡឹកហើយទិញអីគេនិងមក។

ក៖ បាទ! យកមកលក់កុង។

ខ៖ បាទ! យកមកលក់នៅនិង។

ក៖ បាទ! ហើយអញ្ចឹងចំណេញបានប៉ុន្មានដែរកុង?

ខ៖ បាទ! កាលនិងខ្ញុំចំណេញបានខ្លះដែរនិង។

កៈ ហើយអញ្ចឹងកាលនិងឥឡូវកម្មួយប៉ុន្មានកុងកាលណុងកុង?

ខៈ បាទ! កាលនិងឥឡូវកម្មួយប្រាំកាកហើយមួយមួយរៀលដែរនិង។

កៈ បាទ! ហើយអញ្ចឹងកាលពីនិងបានថ្លៃដែរកុង?

ខៈ បាទ! ហើយកាលពីជំនាន់និងដល់ហើយ។

កៈ បាទ!
ហើយអញ្ចឹងកុងឪពុកម្ដាយរបស់កុងមានបានប្រាប់ពីខ្សែជីវិតរបស់កុងទេកុងថាគាត់កាលនៅពីក្មេងនិងមានការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់គាត់ហើយនិងពេលបានម្ដាយរបស់កុងគាត់មានប្រាប់ទេកុង?

ខៈ បាទ!
ឪពុកម្ដាយខ្ញុំគ្មានទេមានតែធ្វើស្រែធ្វើចំការទេឪពុកម្ដាយខ្ញុំនិងនោះគាត់អត់មានធ្វើអីទេ។

កៈ បាទ! ហើយអញ្ចឹងគាត់ធ្វើស្រែចំការទេកុង។

ខៈ បាទ!

កៈ បាទ!

ខៈ បាទ!
ដីចំការតាខ្ញុំច្រើនណាស់នាកចង់មួយចំហៀងកោះនិងណាស់ខាងមុខនាគសុទ្ធតែដីចំការរបស់កុងខ្ញុំទេណាស់។

កៈ បាទ! ច្រើនម៉េះកុង។

ខៈ បាទ! ដីចំការគាត់តាំងពីក្បាលកោះរហូតដល់ចុងកោះនិងណាស់។

កៈ បាទ!

ខៈ បាទ! ហើយដីរបស់ចាស់ៗពីដើមអញ្ចឹងណាស់កាលណុង។

កៈ បាទ! ៗ

ខៈ ហើយនឹងៗដីចំការខ្ញុំនិងហោស។

កៈ បាទ!
ហើយអញ្ចឹងកុងធំដែរកុង។ហើយអញ្ចឹងកុងឥឡូវនិងនៅតែដីកុងនៅឡើយតើកុង?

ខ៖ អត់ទេ។

ក៖ បាទ! ពេលមានសង្គ្រាមហើយពេលដាច់ជំនាន់អាពតនិងវិញគេយកកុង។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងគេយករបស់កុងអញ្ចឹងអត់ដណ្តើមគេវិញកុង?

ខ៖ អត់ទេ។

ក៖ បាទ!

ខ៖ ដណ្តើមអត់បានទេ។

ក៖ បាទ! ហើយអញ្ចឹងឲ្យគេទៅកុង?

ខ៖ បាទ! ឲ្យគេទៅណាព្រោះអីគេឲ្យដីគេមកយើង។

ក៖ បាទ! ហើយអញ្ចឹងគេយកដីយើងហើយគេយកដីយើងទៅវិញកុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងដូរគ្នាវិញកុង?

ខ៖ បាទ! ដូចដូរគ្នាវិញនិង។

ក៖ បាទ! ហើយអញ្ចឹងដូចតែស្មើរគ្នាអញ្ចឹងកុង។

ខ៖ បាទ!
ខ្ញុំអត់ដណ្តើមគេទេហើយយើងអត់ថាធ្វើមិចសង្គមវាមានរឿងអញ្ចឹងទៅហើយនិង។

ក៖ បាទ!

ខ៖ ហើយយើងទៅរើបម្រាសមិចរួច។

ក៖ បាទ!
ហើយអញ្ចឹងកុងមានចាំឈ្មោះជីដូនជីតារបស់កុងហើយដូចខាងម្តាយនិងខាងឪពុកកុងមានចាំទេកុង?

ខ៖ ខ្ញុំអត់ចាំទេ។

កៈ បាទ! ហើយអញ្ជឹងកុងអត់ចាំទេកុង?

ខៈ បាទ! ហើយខ្ញុំចាំតែជីដូនជីតានិងម៉ង។

កៈ បាទ!

ខៈ ហើយខ្ញុំចាំជីដូនជីតាខាងឪហើយនិងជីដូនជីតាខាងម្ដាយ។

កៈ បាទ! ហើយអញ្ជឹងខាងលោកឪពុកមានឈ្មោះអីដែរកុង?

ខៈ បាទ!

កៈ បាទ! ហើយអញ្ចេកកុងឈ្មោះជីដូនជីតាខាងលោកឪពុកគាត់មានឈ្មោះអីដែរកុង?

ខៈ ហើយតារបស់ខ្ញុំនិងគាត់ឈ្មោះ តាកៅ។

កៈ បាទ!មានឈ្មោះថា តាកៅ។

ខៈ បាទ! តាកៅហើយយាយគុម ។

កៈ បាទ! ហើយអញ្ជឹងកុងរបស់កុងតាកៅហើយនិងយាយគុម ។

ខៈ បាទ! ហើយខាងម្ដាយខ្ញុំតា ខ្យង់និងឪពុកណា។

កៈ បាទ!

ខៈ ហើយនិងយាយ វ៉ាន់និងម្ដាយ។

កៈ បាទ!

ខៈ បាទ!

កៈ បាទ! ហើយអញ្ជឹងកុងមានសាច់ញ្ញាតិដែរមា
ននៅក្រៅប្រទេសទេកុងដូចជាប្រទេសអាមេរិចហើយនិងប្រទេស កាណាដា
អូស្រ្តាលីនិងថៃវៀតណាមទេ?

ខៈ អត់មានទេ។មានតែកូនខាងខ្ញុំទេ។

កៈ បាទ!

ខៈ ទៅមានប្រពន្ធនៅស្រុកយួន។

កៈ បាទ! ហើយអញ្ចឹងកូនរបស់កុងទៅមានប្រពន្ធនៅស្រុកយួន។

ខៈ បាទ!

កៈ បាទ! ហើយអញ្ចឹងគាត់នៅប្រទេសវៀតណាមនិងតើកុង?

ខៈ បាទ! អត់ទេវាអត់នៅស្រុកយើងនិងតើព្រោះអីវាយកមកនៅនិងតើ។

កៈ បាទ! ហើយអញ្ចឹងគាត់មកនៅនិងគ្រាន់តែប្រពន្ធគាត់ជាជនជាតិវៀតណាមកុង?

ខៈ បាទ!

កៈ បាទ! ហើយអញ្ចឹងគាត់នៅស្រុកនិងទេកុងហើយអញ្ចឹងកុងមានបងប្អូនរបស់កុងមានទៅបម្រើការងារនៅប្រទេសកូរ៉េថៃទេកុង?

ខៈ បាទ! ខ្ញុំអត់មានទេ។

កៈ បាទ! ហើយអញ្ចឹងកុងអត់មានបងប្អូននៅប្រទេសកូរ៉េហើយនិងថៃទេកុង?

ខៈ បាទ!

កៈ បាទ! ហើយអញ្ចឹងកូនរបស់កុងពួកគាត់សុទ្ធតែនៅខ្មែរទាំងអស់កុង?

ខៈ បាទ! ហើយក្រុមគ្រួសារខ្ញុំនៅនិងទាំងអស់និងហើយគ្រាន់តែខ្ញុំមានកូនប្អូនមួយវាទៅជប៉ុនសព្វថ្ងៃនិង។

កៈ បាទ! ហើយអញ្ចឹងកុងមានប្អូននៅជប៉ុន?

ខៈ បាទ! មិនមែនទេកូនប្អូនទេវាទៅនៅជប៉ុន។

កៈ បាទ! កូនប្អូនទេកុងហើយអញ្ចឹងត្រូវក្មួយរបស់កុង។

ខៈ បាទ! ហើយប្អូនខ្ញុំនិងបានមួយ។

កៈ បាទ! គាត់ទៅនៅជប៉ុន។

ខៈ បាទ! បានមួយទៅនៅជប៉ុន។

កៈ បាទ! ហើយអញ្ចឹងគាត់ទៅនៅយូរន្ទូវកុង?

ខ៖ អរវានិងទៅនៅយូរហើយពីរបីឆ្នាំហើយនិង។

ក៖ បាទ! គាត់បានទៅពីរបីឆ្នាំហើយកុង?

ខ៖ បាទ! ហើយប៉ុន្តែម្តាយស្លាប់អស់ហើយ។ហើយម្តាយនិងមានឈ្មោះ ភួច
និងឪពុកនិងឈ្មោះ ពូច។

ក៖ បាទ! ហើយអញ្ជឹងនិងប្អូនទីបួន។

ខ៖ បាទ! អាប្អូនបន្ទាប់ពីខ្ញុំនិងណាស់។

ក៖ បាទ!

ខ៖ បាទ! ខ្ញុំហើយបានពូចនិងណាស់។

ក៖ បាទ! ហើយអញ្ជឹងគាតនិងកូនទីបួន។ហើយអញ្ជឹងបងពូចនិងគាត់ស្លាប់ហើយតើកុង?

ខ៖ បាទ! គាត់និងនៅទេ។

ក៖ បាទ! ហើយអញ្ជឹងគាត់នៅទេកុង។

ខ៖ បាទ! គាត់នៅតែគាត់និងឈឺ។

ក៖ បាទ! ហើយអញ្ជឹងគាត់នៅរស់ទេប៉ុន្តែគាត់ឈឺនៅផ្ទះកុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ជឹងកូនគាត់ទៅដល់ជប៉ុនហើយមានអីទេ?

ខ៖ បាទ!

ក៖ បាទ!
គាត់បានកូនគាត់ជួយគាត់ហើយ។ហើយអញ្ជឹងកូនគាត់ទៅនៅឬគាត់នៅបម្រើការងារនិង
ប្រទេសជប៉ុនកុង?

ខ៖ វានិងទៅធ្វើការទេអត់ទៅនៅទេ។

ក៖ បាទ! ហើយអញ្ជឹងគាត់ទៅធ្វើការឲ្យគេកុង?

ខ៖ បាទ!ៗ

កៈ បាទ! ហើយអញ្ចឹងគាត់ប្រលងជាប់កុង។

ខៈ បាទ! ខ្ញុំអត់ដឹងថាធ្វើមិចបានគាត់ជាប់ទេណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំអត់ដឹងព្រោះអីខ្ញុំនៅនេះដែរណាស់។

កៈ បាទ!

ខៈ បាទ! ហើយវានៅឯជម្ពុះវ័ន្ត។

កៈ បាទ! ហើយអញ្ចឹងគាត់នៅដល់ជម្ពុះវ័ន្តកុង?

ខៈ បាទ!
ហើយពីមុនវានៅនិងទេហើយវាមានកូនទៅធ្វើការនៅនិងទៅហើយណាមួយអត់មានម្ដាយនិងប្រពន្ធទៅហើយក៏ទៅនៅនិងទៅ។

កៈ បាទ!

ខៈ បាទ!
ហើយពេលទៅនៅជម្ពុះវ័ន្តនិងទៅហើយកូនស្រីពៅនិងទៅធ្វើការនៅជប៉ុននិងទៅណាស់។

កៈ បាទ! ហើយអញ្ចឹងគាត់ទៅធ្វើការនៅជប៉ុនទេ។

ខៈ បាទ! កូនស្រីនិងណាស់។

កៈ បាទ!ៗ

ខៈ ហើយខ្ញុំនិងក៏នៅតែឯងនិងទៅណាស់។

កៈ បាទ!

ខៈ ហើយវានិងក៏នៅជាមួយបងបងពូចនិងទៅណាស់។

កៈ បាទ!

ខៈ នៅជាមួយបងដល់សព្វថ្ងៃនឹងទៅ។

កៈ បាទ!

ខ៖ បញ្ចុកបាយបញ្ចុកបបរនឹងទៅ។

ក៖ បាទ!តែកុងនៅកោះឧញ្ញាតីនឹងតាម្នាក់ឯងទេ?

ខ៖ រាល់ថ្ងៃនឹងខ្ញុំនៅកោះឧញ្ញាតីនឹង២នាក់។

ក៖ អរបាទ!

ខ៖ ខ្ញុំនៅជាមួយអាប្អូនទី៥។

ក៖ បាទ!កុងនៅជាមួយប្អូនពៅ?

ខ៖ បាទ!ខ្ញុំនៅជាមួយប្អូនពៅនឹង។

ក៖
បាទ!ចឹងកុងបើនិយាយពីអាពាហ៍ពិពាហ៍របស់កុហវិញតើភារិយារបស់កុងតើគាត់មាន
ឈ្មោះអ្វីដែលកុង?

ខ៖ ភារិយារបស់ខ្ញុំនឹងគាត់មានឈ្មោះថា យាយ ឆាត។

ក៖ អរគាត់ឈ្មោះយាយ ឆាត?

ខ៖ បាទ!នឹងហើយភារិយាខ្ញុំគាត់ឈ្មោះយាយ
ឆាតយាយឆាតនឹងមិនមែននៅនឹងទេគាត់ជាអ្នកនៅខេត្តកំពងចាម។

ក៖ បាទ!ចឹងកុងទៅរកស៊ីនៅខេត្តកំពងចាមទៅក៏បានស្គាល់គ្នាទៅ?

ខ៖ អត់ទេចាស់ៗគាត់ចាអ្នកនាំទៅ។

ក៖ អឬចាស់ៗគាត់ជាអ្នកនាំទៅ?

ខ៖ បាទ!ចាស់ៗគាត់ជាអ្នកនាំទៅ។

ក៖ បាទ!ជាលក្ខណះថាចាស់ៗគាត់ជាអ្នកផ្សំផ្គុំមពីនោះមកបានគេណែនាំអោយកុងទៅ?

ខ៖ បាទ!

ក៖ បាទ!កូនគេស្អាត់ហើយ?

ខ៖ អត់ទេមិនសូវស្អាត់ប៉ុន្មានដែលទេគ្រាន់ទេម៉ារល្មមម៉ារមធ្យមអីនឹង។

កៈ បាទ!ចឹងតើគាត់រាល់ថ្ងៃនឹងគាត់នៅរស់ឬមួយក៏គាត់បានស្លាប់ហើយកុង?

ខៈ បាទ!គាត់នៅនឹងតា។

កៈ បាទ!គាត់នៅនឹងប៉ុន្តែរ៉ាថ្ងៃនឹងតើគាត់នៅរស់ឬមួយក៏គាត់បានស្លាប់ហើយកុង?

ខៈ អត់ទេគាត់នៅទាំងអស់គ្នានឹង។

កៈ អរបាទ!ចឹងនៅនឹងទាំងអស់គ្នា?

ខៈ បាទ!

កៈ បាទ!ចឹងតើសព្វថ្ងៃនឹងតើគាត់មានអាយុប៉ុន្មានឆ្នាំហើយកុង?

ខៈ ប្រពន្ធខ្ញុំរាល់ថ្ងៃនឹងគាត់មានអាយុ៧០ឆ្នាំជាងហើយ។

កៈ អរបាទ!ចឹងគាត់មានអាយុ៧០ឆ្នាំជាងហើយចឹងគាត់មានអាយុប្អូនកុង?

ខៈ បាទ!គាត់មានអាយុប្អូនខ្ញុំ។

កៈ
បាទ!ចឹងកុងខ្ញុំសូមសួរបន្តិចថានៅពេលដែលកុងបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយតើកុងមានកូនប៉ុន្មាននាក់ហើយកុង?

ខៈ
ខ្ញុំពេលរៀបការចាមួយប្រពន្ធខ្ញុំនឹងបានកូន៥នាក់ស្លាប់អស់ខ្លះហើយនៅសល់តែ៤នាក់ទេ។

កៈ អរបាទ!ចឹងកូនកុងបានស្លាប់អស់១នាក់?

ខៈ បាទ!ស្លាប់អស់២តែស្លាប់១ទេ។

កៈ បាទ!ចឹងតើកូនរបស់កុងនឹងតើមានប្រុសប៉ុន្មានស្រីប៉ុន្មានដែលកុង?

ខៈ ខ្ញុំមានកូនស្រីបានតែ១នាក់នឹង។

កៈ បាទ!អរចឹងកូនកុងមានប្រុស៤នាក់ស្រី១នាក់?

ខៈ បាទ!

កៈ បាទ!ចឹងប្រុស៤នាក់ស្រី១នាក់ទាំងអស់?

ខ៖ បាទ!

ក៖ បាទ!ចឹងបងស្រីគាត់បងគេ?

ខ៖
អត់ទេកូនស្រីនឹងកើតក្រោយអាពតទេទល់តែមួយទៀតបានបងគេតែវាស្លាប់បាត់ហើយ។

ក៖ បាទ!ចឹងអ្នកដែលស្លាប់នឹងតើគាត់មានឈ្មោះអ្វីដែលកុង?

ខ៖ អ្នកដែលស្លាប់នឹងឈ្មោះ ធីដា។

ក៖ អរឈ្មោះ ធីដាបាទហើយចុះប្អូនទី២កុងតើគាត់មានឈ្មោះអ្វីដែលកុង?

ខ៖ កូនទី២ឈ្មោះ រ៉ាត។

ក៖ បាទ!ឈ្មោះ រ៉ាត?

ខ៖ បាទ!

ក៖ បាទ!ហើយឈ្មោះមួយទៀតកុង?

ខ៖ ទី៣នឹងឈ្មោះ ខន។

ក៖ បាទ!ឈ្មោះ ខន?

ខ៖ ខននឹងបងវានឹង។

ក៖ បាត!ហើយបន្ទាប់មកបានបងស្រី?

ខ៖ បាទ!នឹងហើយរួតវានឹងបានខេីញមួយទៀត។

ក៖ បាទ!ប្អូនគេឈ្មោះ ខេីញមួយទៀតបាទចឹងតើបងស្រីគាត់មានឈ្មោះអ្វីដែលកុង?

ខ៖ បងស្រីនឹងវាឈ្មោះ សុភន្ទ។

ក៖ អរគាត់ឈ្មោះ សុភន្ទ?

ខ៖ បាទ!

ក៖ បាទ!ចឹងពេលនឹងតើកុងរៀបអាពាហ៍ពិពាហ៍នៅនឹងឬមួយរៀបការនៅកំពងចាមកុង?

ខ៖ ពេលនឹងខ្ញុំរៀបចំអាពាហ៍ពិពាហ៍នៅកំពងចាម។

កៈ អរបាទ!ចឹងកុងរៀបចំនៅខាងស្រីទេ?

ខៈ បាទ!ពេលនឹងខ្ញុំរៀបចំនៅខាងស្រីទេ។

កៈ
បាទ!ចឹងកុងរៀបការជាមួយភារិយាកុងនឹងនៅឆ្នាំណាដែលកុងមុនអាពតឬក៏ក្រោយអាពតកុង?

ខៈ ពេលនឹងខ្ញុំរៀបការមុនអាពត។

កៈ បាទ!កុងរៀបការមុនអាពតចឹងកុងរៀបការកាលជំនាន់លន់នល់?

ខៈ បាទ!កាលជំនាន់លន់លន់នឹង។

កៈ បាទ!ចឹងកុងរៀបការនៅជំនាន់នឹង?

ខៈ បាទ!ការនឹងខ្ញុំនៅធ្វើការនៅកន្លែងចំការដេរនឹងតា។

កៈ អរកុងធ្វើការនៅនឹង?

ខៈ បាទ!យាយៗនៅនោះគាត់ពេញចិត្តខ្ញុំគាត់ណែនាំអោយខ្ញុំទៅ។

កៈ
អរបាទ!ចឹងកុងពេលនឹងកុងស្អាតដែរនឹងបាទចឹងពេលនឹងកុងបានជូនចំណូនអោយខាងស្រីចំនួនប៉ុន្មានដែលកុងថ្លៃទឹកដោះនឹងណាស់កុងតើចំនួនប៉ុន្មានដែលកុង?

ខៈ កាលនឹងខ្ញុំជូនអោយខាងស្រីតារ៣ពាន់នឹង។

កៈ កាលនឹង៣ពាន់ថ្លៃកុង?

ខៈ
បាទ!កាលនឹងថ្លៃ៣ពាន់នឹងកាលនឹងពេលខ្ញុំការអត់ទាន់មានអ្នកណារៀបតុកទេមានតារខ្ញុំមួយជាអ្នករៀបចំតុកក្រៅពីនឹងគ្មានពីណាគេរៀបទេ។

កៈ បាទ!ចឹងពេលនឹងតើកុងរៀបការនឹងកុងដាក់ប៉ុន្មានតុកដែរកុង?

ខៈ កាលនឹងខ្ញុំរៀបចង២០តុកដែលនឹង។

កៈ អរកាលនឹងច្រើនណាស់ធំ២០តុក?

ខ៖ បាទ!ហើយធុងបាសទល់តែភ្លឺទៀតបងថ្លៃប្អូនថ្លៃអីគាត់ចេះលេងភ្លេងច្រៀងលេងទាល់តែភ្លឺសប្បាយណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំទៅនិងដូចថាខ្ញុំទៅបង្រៀនគេអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងទៅនិងដូចបង្រៀនគេកុង។

ខ៖ បាទ! ហើយការខ្ញុំរួចទៅហើយនិងអ្នកក្រោយៗនិងគេធ្វើតាមខ្ញុំនិងណាស់រៀបតុដូចគ្នាអញ្ចឹងទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងជាមេនាំអាត់មុនគេកុង។

ខ៖ បាទ! ខ្ញុំរៀបតុនិងទៅណាស់ហើយគេធ្វើតាមខ្ញុំទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងគេឃើញកុងរៀបតុហើយគេមានតុដែរទៅកុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងគេឃើញកុងរៀបចំតុអញ្ចឹងទៅឡូយហើយអញ្ចឹងគេធ្វើតាមទៅណាស់។

ខ៖ បាទ! គេឃើញថាយើងធ្វើទៅស្អាត់ហើយឡូយហើយគេធ្វើតាមទៅណាស់។

ក៖ បាទ!

ខ៖ ហឺសប្បាយណាស់កាលណុងនោះ។

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីការរៀនរបស់កុងអញ្ចឹងតើរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរកុង?

ខ៖ ខ្ញុំអត់បានរៀនទេតែខ្ញុំចេះតិចណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងចេះដែរតែបានតិចកុង។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងកុងអាចសរសេរបានអត់កុង?

ខ៖ អត់បានទេ។

ក៖ បាទ! ហើយអញ្ចឹងកាលនៅពីក្មេងក៏មិនអាចសរសេរបានដែរកុង?

ខ៖ បាទ! ហើយខ្ញុំកាលនៅពីក្មេងនិងខ្ញុំអាចសរសេរបានខ្លះដែរណាស់ហើយតែឥឡូវនិងខ្ញុំវែកអីហើយឥឡូវនិងនោះ។

ក៖ បាទ! ហើយអញ្ចឹងកុងអាចអានបានទេកុង?

ខ៖ អត់ទេ។

ក៖ បាទ! ហើយអញ្ចឹងកុងអត់អាចអានបានទេកុង?

ខ៖ បាទ!

ក៖ ហើយអញ្ចឹងកុងកាលនៅពីក្មេងនិងកុងអាចអានបានហើយនិងសរសេរបានកុង?

ខ៖ បាទ! កាលខ្ញុំនៅពីក្មេងនិងខ្ញុំអាចអានបានដែរ។

ក៖ បាទ! ហើយអញ្ចឹងកុងអាចអានបានដែរកុង?

ខ៖ បាទ! ហើយដល់ពេលចាស់ទៅខ្ញុំវល់អត់ហើយ។

ក៖ បាទ! ហើយអញ្ចឹងកុងចាស់ហើយកុងភ្លេចអត់ហើយកុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងដូចយើងចាស់តាមវ័យអញ្ចឹងណាស់ហើយអញ្ចឹងខួរក្បាលយើងនិងក៏ចាស់ដែរកុង។

ខ៖ បាទ! ហើយខ្ញុំអត់សូវចាំទេ។

ក៖ បាទ!

ខ៖ បាទ! ហើយពេលខ្លះខ្ញុំនិយាយបានមួយភ្លេតនិងខ្ញុំភ្លេតអស់ហើយ។

ក៖ បាទ ! ហើយអញ្ចឹងកុងបើនិយាយពីភាសាបរទេសអញ្ចឹងកុងក្រៅពីភាសាខ្មែរដូចជាភាសាអង់គ្លេស បារាំង ថៃ វៀតណាមហើយអញ្ចឹងកុងមានចេះទេកុង?

ខ៖ ខ្ញុំអត់ចេះទេ។

ក៖ បាទ! ហើយអញ្ចឹងកុងអត់ចេះទេកុង?

ខ៖ បាទ! ខ្ញុំអត់ចេះទេ។

ក៖ បាទ! ហើយអញ្ចឹងកុងចេះតែភាសាខ្មែរទេកុង?

ខ៖ បាទ! ខ្ញុំចេះតែភាសាខ្មែរទេកុង?

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីមិត្តភក្តិជិតស្និតកុងមានមិត្តភក្តិជិតស្និតទេកុង?

ខ៖ បាទ! ខ្ញុំមានតើអត់យកទៅណាទេពេញតែភូមិនិង។

ក៖ បាទ! ហើយអញ្ចឹងកុងមានមិត្តភក្តិពេញម៉ាភូមិកុង។

ខ៖ បាទ! ខ្ញុំមានមិត្តភក្តិនិងពេញម៉ាភូមិនិងណាស់។

ក៖ បាទ !

ខ៖ ហើយទៅសួរអ្នកណាក៏ស្គាល់ខ្ញុំដែរ។

ក៖ បាទ!
ហើយអញ្ចឹងកុងនិយាយពីមិត្តភក្តិជាមួយគ្នាមិត្តមួយថ្លើមមួយជាមួយគ្នានិងកុងមានទេកុង?

ខ៖ បាទ! ខ្ញុំមានតើតែស្លាប់អស់ខ្លះហើយ។

ក៖ បាទ! ហើយអញ្ចឹងគាត់បានស្លប់អស់ខ្លះហើយកុង?

ខ៖ បាទ! ពួកគាត់និងបានស្លាប់ខ្លះអស់ហើយនិង។

ក៖ បាទ!

ខ៖ បាទ! ហើយអាទៅរកគ្រួសជាមួយគ្នានិងស្លាប់អស់ហើយនិង។

ក៖ បាទ! ហើយអញ្ចឹងមិត្តរបស់កុងបានស្លាប់អស់ខ្លះហើយដែរកុង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងកុងប្រហែលប៉ុន្មាននាក់ដែរកុង?

ខ៖ បាទ!

កៈ បាទ! ហើយកុងមានមិត្តភក្តិជិតស្និតនិងប៉ុន្មាននាក់ដែរកុង?

ខៈ បាទ! ខ្ញុំមានច្រើនដែរនិងប្រហែលបួនដប់នាក់ដែរនិង?

កៈ បាទ!

ខៈ បាទ! មិត្តភក្តិនិងមានច្រើនណាស់។

កៈ បាទ!

ខៈ បាទ! ពីព្រោះខ្ញុំកាលនិងខ្ញុំនៅអេស្កាដេហើយខ្ញុំមិនមែននិយាយអួតទេណាស់។

កៈ បាទ!

ខៈ
ហើយបើនិយាយរឿងផឹកស៊ីឲ្យតែថ្ងៃសៅរ៍និងថ្ងៃអាទិត្យនិងព្រឹកឡើងយួរមួយកន្ត្រាវៗនិងមកណាស់។

កៈ បាទ! ហើយអញ្ជឹងគាត់យួរមួយកន្ត្រាវមកហើយកាប់មាន់មួយកុង។

ខៈ បាទ! ហើយអាណាគេមានមាន់ហើយគេកាប់ស៊ីទៅណាស់។

កៈ បាទ!

ខៈ
ហើយអាណាស៊ីអីស៊ីទៅហើយអញមានតែស្រាហើយអត់ស្រាដើរវង់ទិញស្រាផឹកទៀត។

កៈ បាទ! ហើយអញ្ជឹងកុងដើរផឹកទៀតកុង។

ខៈ បាទ!

កៈ ហើយអញ្ជឹងកាលនិងកុងសប្បាយដែរកុង?

ខៈ បាទ! កាលនិងសប្បាយណាស់។

កៈ បាទ !

ខៈ បាទ! កាលពីជំនាន់និងសប្បាយណាស់។

កៈ បាទ! កាលពីជំនាន់និងមានទៅវាយគ្នាអីផឹកហើយដេកលើគ្នាទៀតកុង។

ខ៖ បាទ! អត់មា
នការពិបាកទេកាលនិងអត់មានការវាយគ្នាទេដេកលើគ្នាហើយក្របមកជឹកដៃគ្នាទៅទៀត
។

ក៖ បាទ!

ខ៖ ហើយកាលនិងស្រវឹងស្រលប់ហើយបាត់ស្មារតីឆឹង។

ក៖ បាទ! ហើយដេកគង់ជើងគ្នាហើយព្រឹកឡើងគេសគ្នាព្រៀត។

ខ៖ បាទ! ហើយព្រឹកឡើងគេសគ្នាផឹកទៀត។

ក៖ បាទ! គេសគ្នាផឹកទៀត។

ខ៖ បាទ! កាលនិងសប្បាយណាស់ប្អូនអើយ។

ក៖ បាទ! ហើយអញ្ចឹងកុងមានចាំឈ្មោះពួកគាត់ទេកុង?

ខ៖ បាទ!

ក៖ បាទ!
ហើយអញ្ចឹងកុងមានចាំឈ្មោះពួកគាត់ទេកុង?ហើយដូចថាមិត្តភក្តិរបស់កុងមានចាំឈ្មោះ
ពួកគាត់ទេកុង?

ខ៖ បាទ! ខ្ញុំចាំតែមានភ្លេចខ្លះហើយណាស់អ្នកនៅកោះយើងនិងមានការភ្លេចខ្លះហើយ។

ក៖ បាទ!

ខ៖ មានឈ្មោះថា ថាយ៉ុង ។

ក៖ បាទ! អត់អីទេកុងបើកុងភ្លេចក៏អត់អីដែរកុង?

ខ៖ បាទ! អត់អីទេ។

ក៖ បាទ! ព្រោះអីកុងមានការភ្លេចច្រើន។

ខ៖ បាទ! ឈ្មោះ សុខឈ្មោះអីមានឈ្មោះពីរនាក់និងណាស់។

ក៖ បាទ!

ខ៖ អាយ៉ុង អាសុខ អាផុន ហើយនិងអា យ៉ុន ។

ក៖ បាទ!

ខ៖ បាទ! ហើយអាយ៉ុននិងវានៅនិងទេ។

ក៖ បាទ!
ខ៖ បាទ! ប៉ុន្តែខ្វាក់ភ្នែកងងឹតហើយណាស់។

ក៖ បាទ!

ខ៖ វារាល់ថ្ងៃនិងនៅមុខវត្ត។

ក៖ បាទ! គាត់នៅមុខវត្តកុង។

ខ៖ បាទ!

ក៖ បាទ!

ខ៖ បាទ! និងហើយអាយ៉ុននិងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយអាយ៉ុននិងងងឹតនិងហើយចង់ទៅណាអីចាំក្មេងដឹកដៃនិង។

ក៖ បាទ!
ហើយអញ្ចឹងកុងបើនិយាយពីកុងនៅពីក្មេងនិងកុងអត់មានដែរធ្លាប់ដកស្ទូងធ្វើស្រែធ្វើចំការឲ្យគេទេកុង?

ខ៖ បាទ! ខ្ញុំអត់ដែរធ្លាប់ស៊ីឈ្នួលដកស្ទូងធ្វើស្រែធ្វើចំការគេទេ។

ក៖ បាទ ! ហើយអញ្ចឹងរកគ្រួស។

ខ៖ បាទ! បើខ្ញុំធ្វើការងាររដ្ឋតែម្តង។

ក៖ បាទ! ហើយអញ្ចឹងកុងចង់ធ្វើការងាររដ្ឋម៉ងកុង?

ខ៖ បាទ!

ក៖ បាទ!

ខ៖ ហើយអញ្ចឹងធ្វើការខ្លួនឯងម៉ងមុះគ្រួស។

កៈ បាទ! ហើយអញ្ជឹងធ្វើការឲ្យរដ្ឋកាលនិងបានប្រាក់ខែប៉ុន្មានដែរកុង?

ខៈ បាទ! កាលនិងខ្ញុំបានប្រាក់ខែ១២០០។

កៈ បាទ! កុងបានប្រាក់ខែច្រើនហើយអញ្ជឹងបានកុងការផ្អើលភូមិកុង?

ខៈ បាទ!

កៈ ហើយអញ្ជឹង១២០០កាលណុងច្រើនណាស់កុង?

ខៈ បាទ!
១២០០កាលច្រើនណាស់ហើយកាលនិងខ្ញុំនៅបានយូរៗទៅហើយខ្ញុំចាប់បានចោលអីនិងទៅហើយអ្នកធំគេស្រឡាញ់ហើយគេលើកខ្ញុំនិងឲ្យបានប្រាក់ខែទៀត។

កៈ បាទ! ហើយអញ្ជឹងចាប់បានចោលច្រើនបានគេដំឡើងប្រាក់ខែឲ្យទៀតកុង?

ខៈ បាទ! កាលណុងគេឲ្យខ្ញុំនិងទៅនៅក្រោយវាំងនិង។

កៈ បាទ! ហើយអញ្ជឹងគេឲ្យកុងទៅក្រោយវាំងកុង?

ខៈ បាទ!

កៈ បាទ!

ខៈ បាទ! គេឲ្យខ្ញុំនៅក្រោយវាំងនិងអគារបួនជាន់កាលណុងណាស់។

កៈ បាទ !

ខៈ បាទ! ខ្ពស់ណាស់ខ្ពស់ស្រលឹម។

កៈ បាទ!

ខៈ បាទ! ហើយគេឲ្យទៅនៅប្រេវ៉ូបួនជាន់និងណាស់។

កៈ បាទ!

ខៈ បាទ!
ហើយគេខ្ញុំយាមប្រេវ៉ូនិងហើយបានបួនឆ្នាំហើយគេធ្វើប្រេវ៉ូថ្មីនិងហើយគេឲ្យខ្ញុំនិងទៅយាមប្រេវ៉ូនិងមួយទៀតនៅខាងត្បូងនិងណាស់។

កៈ បាទ!

ខ៖ បាទ! ហើយឥឡូវនិងគេវាយចោលហើយ។

ក៖ បាទ!

ខ៖ ហើយគេធ្វើអីទៀតហើយ។

ក៖ បាទ!

ខ៖ ហើយណុងបួនជាន់ដែរ។

ក៖ បាទ! ហើយនៅណុងបួនជាន់ដែរ។

ខ៖ បាទ!
នឹងហើយ។ហើយរួចនិងអាពតចូលហើយនៅបានប៉ុន្មានឆ្នាំបីបួនឆ្នាំនិងអាពតចូល។

ក៖ បាទ!

ខ៖ បាទ! ហើយគេដាក់ខ្ញុំឲ្យទៅយាមអាពតនៅកំបូល។

ក៖ បាទ! ហើយអញ្ចឹងកុងយាមនៅខាងកំបូលវិញកុង?

ខ៖ បាទ!
ហើយទៅគេឲ្យខ្ញុំទៅបើកកាំភើងមួយព្រឹកហើយបើកអត់បានហើយគេថាទាល់តែសុំសំបុត្រពីអ្នកធំបានកើត។

ក៖ បាទ!

ខ៖ បាទ! ហើយកាំភើងនិងបានបើកកើតហើយគេទាល់តែម៉ោងពីរបានបានមក។

ក៖ បាទ!

ខ៖ បានបើកបានហើយពីព្រោះយើងទៅពីព្រឹកបើកអត់បានណាស់។

ក៖ បាទ!

ខ៖ បាទ!
ម៉ោងពីរឲ្យទៅទៀតហើយដល់ទៅទៀតខ្ញុំបានមកដល់ប្រវ៉ូហើយខ្ញុំខ្ចីម៉ូតូកុងស៊ុនហើយយុងមកផ្ទះ។

ក៖ បាទ!

ខ៖ ហើយខ្ញុំមកប្រាប់ប្រពន្ធកូនខ្ញុំឲ្យដឹងថាខ្ញុំគេបញ្ជូនហើយ។

ក៖ បាទ!

ខ៖ ហើយគេបញ្ជូនយាមអាពតនៅកំបូលឯណុង។

ក៖ បាទ!

ខ៖ ហើយម្ដាយខ្ញុំអើយគាត់យំស្រែកអើយគាត់នៅអាល័យខ្ញុំ។

ក៖ បាទ!

ខ៖ បាទ! ហើយគាត់ថាខ្ញុំទៅទៀតមុខតែអស់ពូជហើយ។

ក៖ បាទ!

ខ៖ ហើយមិនស្រួលងាប់ចោលម៉ែចោលឪហើយ។

ក៖ បាទ!

ខ៖ ហើយចោលប្រពន្ធកូនហើយ។

ក៖ បាទ !

ខ៖ ហើយខ្ញុំទៅពីនិងទៅដល់ប្រវ៉ូ។

ក៖ បាទ!

ខ៖
ហើយពួកអ្នកយាមៗនិងមកប្រាប់ខ្ញុំថាអាលន់អត់ទេលោកដេព័ទ្ធលោកហៅមេៗប្រជុំហើយ។

ក៖ បាទ!

ខ៖
លោកដេព័ទ្ធហៅប្រជុំឈ្មោះណាទៅខ្លះគេប្រាប់ថាឈ្មោះនេះមួយឈ្មោះនោះមួយហើយគេថាឈ្មោះអាលន់មួយលោកដេព័ទ្ធទះតុផាង។

ក៖ បាទ! គាត់ផាងតុ។

ខ៖ ហើយគាត់ថាអត់បានទេអាលន់។

ក៖ បាទ!

ខ៖ ហើយគាត់ថាក្រៅពីអាលន់យកអ្នកណាអ្នកទៅ។

ក៖ បាទ!

ខ៖ ហើយលោកមានប្រសាសន៍ដ៏ប៉ុណ្ណឹងណាស់។

ក៖ បាទ! គាត់ចូលចិត្តកុង។

ខ៖ បាទ! ខ្ញុំអត់ដឹងថាលោកគាត់ស្អប់ខ្ញុំក៏មិនដឹងហើយគាត់ស្រឡាញ់ខ្ញុំក៏មិនដឹង។

ក៖ បាទ! គាត់ស្រឡាញ់ហើយបានគាត់អត់បញ្ជូនទៅកុង?

ខ៖ បាទ! ហើយគាត់ថាក្រៅពីអាលន់យកអ្នកណាក៏យកទៅ។

ក៖ បាទ!

ខ៖ ហើយខ្ញុំអត់ដែរហ៊ាននិយាយប្រាប់គេប្រាប់ឯងទេណាស់។

ក៖ បាទ!

ខ៖ ទើបតែនិយាយនឹងទេនាក។

ក៖ បាទ!

ខ៖ ខ្ញុំខ្មាស់គេណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំខ្លាចគេថាលោកនិងវាស្អីបានអ្នកធំគេមិនឲ្យខ្ញុំទៅ។

ក៖ បាទ!

ខ៖ ហើយមកពីខ្ញុំត្រង់។

ក៖ បាទ!

ខ៖ ហើយខ្ញុំវាយចោរនិងក៏បានហើយអាលុយក្នុងប្រវ៉ូនិងអាពួកចិនវាទិញស្រាទៅណាស់។

ក៖ បាទ!

ខ៖ ហើយវាយកលុយមកឲ្យគាត់វិញណាស់។

ក៖ បាទ!

ខ៖ ហើយលុយកម្ពស់និងលុយ(ប្រហែល0.5m)។

ក៖ បាទ! អត់បាត់។

ខ៖ បាទ! អត់បាត់ទេហើយគាត់ទទួលលុយបានហើយអាចិននិងបបួលគាត់ទៅហូបគុយទាវ។

ក៖ បាទ!

ខ៖ បាទ! ហូបគុយទាវកាហ្វេនិងទៅហើយគាត់ក៏ទៅទៅហើយអត់ចាប់ផ្តឹករឿងលុយនៅលើតុឯណា។

ក៖ បាទ!

ខ៖ ហើយម៉ោង១១ទៅ១២។

ក៖ បាទ! ម៉ោ១២យប់មែនកុង?

ខ៖ អត់ទេម៉ោង១២ថ្ងៃនិង។

ក៖ បាទ!

ខ៖ ហើយខ្ញុំក៏ឡើងទៅបិទទ្វារនិងបិទបង្អួចហើយទៅលុយគរនៅលើតុកម្ពស់បីបួនជុងនិង។

ក៖ បាទ!

ខ៖ ហើយលុយកម្ពស់ប៉ុណ្ណឹងៗហើយអត់ដឹងថាប៉ុន្មានលានទេលុយនិង។

ក៖ បាទ!

ខ៖ ហើយខ្ញុំអត់យកទៅហើយខ្ញុំគ្រាន់តែឃើញលុយនិងខ្ញុំញ៉ាក់សាច់ម៉ងនិង។

ក៖ បាទ!

ខ៖ បាទ! ហើយខ្ញុំបើកថតតុមើលៗហើយបើកទាំងពីរនិងឃើញសៀវភៅនៅពេញនិង។

កៈ បាទ!

ខៈ បាទ! ហើយខ្ញុំលើកសៀវភៅដាក់ក្នុងៗហើយលុយខ្ញុំដាក់ក្នុងថតតុ។

កៈ បាទ! ទុកឲ្យគាត់។

ខៈ បាទ! ទុកឲ្យគាត់មកវិញ។

កៈ បាទ!

ខៈ ស្រាប់តែដល់ម៉ោងហើយគាត់នឹកឃើញលុយហើយគាត់មក។

កៈ បាទ!

ខៈ ហើយលុយដាក់នៅនិងហើយខ្ញុំចុះពីប្រវ៉ូបួនជាន់និងមកហើយខ្ញុំអង្គុយមាត់ទ្វារនិង។

កៈ បាទ!

ខៈ ហើយគាត់ភ័យគាត់។

កៈ បាទ!

ខៈ ហើយលុយគាត់ច្រើននៅលើកតុនិង។

កៈ បាទ!

ខៈ ហើយគាត់បើកឡានលឺងោងៗម៉ងហើយគាត់ចាប់ប្រាំងផិតៗនៅមុខប្រវ៉ូនិង។

កៈ បាទ!

ខៈ បាទ! ហើយខ្ញុំចេញទៅហើយគាត់ថាអាលន់ៗហើយគាត់ថាឯងមានឃើញលុយអញអត់ហើយខ្ញុំថាឃើញគេជគុនៗហើយគាត់ថាហើយអញ្ជឹងទៅៗហើយនិយាយពីគាត់រត់លឿនជាងខ្ញុំទៀត។

កៈ បាទ!

ខៈ ហើយគាត់ឡើងព្រុសៗហើយខ្ញុំនៅក្រោមនិងគាត់ហៅហើយខ្ញុំរត់ឡើងទៅហើយគាត់ឡើងទៅទៀតហើយបានបួនជាន់បានខ្ញុំឡើងទៅដល់។

កៈ បាទ!

ខៈ
ពេលទៅដល់គាត់ថាអាលន់អើយនៅណាលុយៗហើយខ្ញុំចាក់សោរហើយបើកទ្វារឲ្យគាត់ចូលទៅហើយគាត់មើលលើតុអត់ឃើញលុយគាត់ថាឯណាលុយៗអាលន់ៗហើយខ្ញុំថាលុយនៅនិងទេតេជគុនៗ។ហើយគាត់ថាឯងមានយកទេហើយខ្ញុំថាខ្ញុំអត់ទេៗខ្ញុំភ័យណាស់ខ្ញុំអត់ហ៊ានទេតេជគុន។

កៈ បាទ!

ខៈ ហើយខ្ញុំថាអត់ហ៊ានទេហើយខ្ញុំបើកថតតុមើលហើយលើកដាក់ម៉ងណាស់។

កៈ បាទ!

ខៈ ហើយបើថតទូរមួយទៀត។

កៈ បាទ!

ខៈ ហើយទាញ់លុយមកដាក់លើតុនិងទៀត។

កៈ បាទ!

ខៈ
ហើយគាត់ថាឯងមានយកទេហើយខ្ញុំថាអត់ទេខ្ញុំអត់ហ៊ានទេរឺឯងមិចអត់យកសោះហើយខ្ញុំថាអត់ទេខ្ញុំអត់យកទេហើយគាត់ថាឯងទុកនិងហើយគាត់ក៏ប្រមូលលុយដាក់ថងគាត់និងទៅហើយគាត់ចេញទៅហើយបានម៉ោងពីរបានមកវិញ។

កៈ បាទ!

ខៈ ហើយបានបីបួនថ្ងៃពួកស៊ីកាទ័រគាត់និងណាស់។

កៈ បាទ!

ខៈ
ហើយប្រវ៉ូនិងបើកទ្វារហើយខ្ញុំចូលទៅបិទអីអញ្ជឹងទៅហើយឃើញម៉ាញ្ញេ(វិទ្យុ)អីនិងនៅលើតុនិងហើយខ្ញុំអត់ប៉ះពាល់ទេហើយខ្ញុំយកទៅដាក់ក្នុងថតតុនិងទៅណាស់។

កៈ បាទ!ៗ

ខៈ ដាក់ថតតុស្រីៗនិងណាស់។

កៈ បាទ!

ខៈ ហើយមិត្តភក្តិបីប្អូននាក់នៅនិងហើយខ្ញុំលើកដាក់ក្នុងថតតុនិងទៅណាស់។

កៈ បាទ!

ខៈ
ពេលគាត់មកពីផ្ទះវិញហើយគាត់បើកថតតុហើយឃើញម៉ាញ្ញេ(វិទ្យុ)និងទៅហើយគាត់នៅស្ងៀមនិងទៅណាស់។

កៈ បាទ!

ខៈ ហើយគាត់ដាក់លុយកាកអីដាក់ចោលនិង។

កៈ បាទ!

ខៈ ហើយខ្ញុំអត់ប៉ះពាល់។

កៈ បាទ! ហើយអញ្ជឹងបានគេស្រឡាញ់កុង។

ខៈ បាទ! ដល់នេះលោកដេព័ទ្ធនិងសម្ទេះសម្ទា។

កៈ បាទ!

ខៈ បាទ!
ហើយគាត់ព្រឹកឡើងមាននំមានអីទេអីគុយទាវអីយកមកហូបជុំគ្នានិងស្រីបីប្អូននាក់និងទៅ។

កៈ បាទ!

ខៈ បាទ!
ហើយគាត់ថាគាត់និយាយសម្ទេះសម្ទាជាមួយស្រីនិងហើយអ្នកនិងក៏បើកនិយាយអញ្ជឹងដែរ។

កៈ បាទ!

ខៈ ហើយបានអ្នកនិងក៏តាមអញ្ជឹងទៅ។

កៈ បាទ!

ខ៖ ហើយគាត់ថាអាល
ន់និងអានឹងវាត្រង់និងម៉ងហើយអានេះអត់មានយករបស់អ្នកណាអ្នកណាអីទេអានឹងត្រង់
ណាស់។

ក៖ បាទ!

ខ៖
អត់យកទៅហើយគាត់ថារបស់ខ្ញុំអញ្ចឹងដៃរលុយខ្ញុំទាំងគីបហើយគាត់សម្ពេះសម្មាហើយគា
ត់ថាតាលន់និងត្រូវមែនតាលន់និង។

ក៖ បាទ!

ខ៖
ហើយគាត់ត្រង់ណាស់អត់ប៉ះពាល់ទេហើយគាត់និយាយបានគាត់គេខ្ញុំនៅក្រោមពីលើនិង
ទៅហើយឲ្យកុងស៊ុនទៅហៅខ្ញុំទៅលើ។

ក៖ បាទ!

ខ៖ ហើយគាត់សួរខ្ញុំអាលន់ឯងហើយដំបូងណាស់។

ក៖ បាទ!

ខ៖
ហើយគាត់ថាអាលន់ឯងព្រឹកឡើងឯងមិនបាច់ទៅស៊ីអីទេហើយឯងមកបើមើលទូរឃើញអី
ស៊ីនិងទៅ។

ក៖ បាទ!

ខ៖ ហើយចាប់ពីម៉ោង៥ទៅម៉ោង៦:៣០និងម៉ោង៧ទៅ៧:៣០អីនិងណាស់។

ក៖ បាទ!

ខ៖ ហើយស៊ីអីៗគេទុកនិងទៅ។

ក៖ បាទ!ៗ

ខ៖ ហើយអាលន់ឯងហើយបើកទូរនិងឃើញស៊ីទៅ។

ក៖ បាទ!

ខ៖ ហើយគាត់ថាឃើញអីខ្លះស៊ីទាំងអស់ទៅកុំទុក។

ក៖ បាទ!

ខ៖
ហើយខ្ញុំម៉ោង១រហូតដល់ម៉ោង៧ហើយខ្ញុំទៅបើកមើលឃើញនំប៉ុងដាក់សាច់ផងហើយអី ហើយផ្លែឈើអីនិងទាំងអស់និងហើយចាននៅនិងទៀត។

ក៖ បាទ!

ខ៖ ហើយខ្ញុំថាអីក៏ទុកអីច្រើនម៉េះ។

ក៖ បាទ! អត់ដឹងថាហូបមួយណាកុង។

ខ៖ ហើយខ្ញុំស៊ីហើយស៊ីម៉ងឆ្អែកនិងហើយស៊ីអត់អស់ទៀត។

ក៖ បាទ!

ខ៖ ហើយរបស់គាត់នៅទុកណុង។

ក៖ បាទ!

ខ៖ ហើយស៊ីបានប្រាំប្រាំមួយថ្ងៃគាត់តេហៅឡើងទៀត។

ក៖ បាទ!

ខ៖ ហើយខ្ញុំឡើងទៅហើយគាត់សួរខ្ញុំថាអាលន់ឯងប្រាក់ខែប៉ុន្មានសព្វថ្ងៃនិង។

ក៖ បាទ!

ខ៖ បាទ! ហើយខ្ញុំថាអត់ទេតេជគុនបាន១២០០ទេតេជគុន។

ក៖ បាទ!

ខ៖
ហើយគាត់ថារី១២០០ហើយខ្ញុំថាបាទហើយឯងធ្វើប៉ាស្តោលមកអញឡើងលុយឲ្យទៀត។

ក៖ បាទ!

ខ៖ ហើយខ្ញុំបានបេកាទ័រនិងគាត់ធ្វើប៉ាស្តោលឲ្យនិង។

កៈ បាទ!

ខៈ គេធ្វើឲ្យដំឡើងលុយឲ្យទៅហើយកាលនិងបានច្រើននិង។

កៈ បាទ!

ខៈ ហើយគាត់សរញ្ញោ(ចុះអត្ថលេខា)ហើយខ្ញុំបើលុយមកបាន១៧០០។

កៈ បាទ! ហើយអញ្ចឹងកុងបានច្រើនជាងគេហើយកុង។

ខៈ បាទ! ហើយកាលនិងបាន១៧០០។

កៈ បាទ!

ខៈ បាទ! ហើយកាលនិងរស់បានស្រួលទៅណាស់។

កៈ បាទ!
ហើយអញ្ចឹងកុងបើនិយាយទាំងពីក្មេងរហូតបានមកដល់ធំនិងតើជីវិតរបស់កុងមានការផ្លាស់ប្ដូរអ្វីខ្លះនៅក្នុងជីវិតរបស់កុងទេកុងមានការសប្បាយច្រើនជាងទុក្ខឬក៏កើតទុក្ខច្រើនជាងសប្បាយអញ្ចឹងកុង?

ខៈ ហើយសុខសប្បាយវាមានការឈឺស្គាត់ដែរណាស់។

កៈ បាទ!

ខៈ មានឈឺស្គាត់បឺសៗអញ្ចឹងដែរណាតែវាមិនទៅ។

កៈ បាទ!

ខៈ ហើយគាត់ទុកឲ្យខ្ញុំនៅតទៅទៀត។

កៈ បាទ! ហើយអញ្ចឹងកុងបើនិយាយពីម្ហូបវិញកុងចូលចិត្តម្ហូបអីជាងគេកុង?

ខៈ បាទ! ហើយខ្ញុំបានទឹកសម្លដែរទេ។

កៈ បាទ! សម្លម្ជូលសម្លសម្លឹក។

ខៈ បាទ! នឹងហើយសម្លឹកប្រហើរអីនិងបាន។

កៈ បាទ!

ខ៖ បាទ! ហើយនិងហើយបើមានត្រីអាំងអីទៀតក៏បានដែរណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយយើងបានទឹកសម្លនិងបានមកស្រូប។

ក៖ បាទ!

ខ៖ បាទ! ហើយស្រូបបាយអីនិងទៅហូបទៅ។

ក៖ បាទ!

ខ៖ ហើយយើងបេះសាច់ត្រីអីតិចទៅណាស់ហូបទៅ។

ក៖ បាទ!

ខ៖ ហើយនិងចេះតែបានហើយព្រោះសាច់មាន់សាច់ទាអត់សោះហើយ។

ក៖ អត់ទេកុង។

ខ៖ បាទ! គ្រាន់តែពងមាន់ក៏ខ្ញុំអត់ដែរ។

ក៖ បាទ!

ខ៖ ហើយខ្ញុំនិងអត់ពាលទេ។

ក៖ បាទ!
ហើយអញ្ចឹងកុងបើនិយាយពីកុងនៅពីក្មេងមកល្បែងប្រជាប្រិយភាពដូចជាចោលឈូង
បោះអង្គុញទាញព្រ័ត្តអីកុងមានចូលចិត្តទេកុង?

ខ៖ ខ្ញុំចូលចិត្តដែរនិង។

ក៖ បាទ! ហើយអញ្ចឹងចូលឆ្នាំខ្មែរម្តងនៅតាមវត្តសប្បាយណាស់កុង?

ខ៖ បាទ! នឹងតាមវត្តនិងហើយបើថាខ្ញុំនៅវត្តគ្មានអ្នកណាដូចខ្ញុំទេ។

ក៖ បាទ!

ខ៖ ដូចបោះឈូងអង្គុញនិង។

ក៖ បាទ! ចូលចិត្តទាំងអស់កុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ជឹងបើការច្រៀងរាំវិញកុងមានចូលចិត្តទេកុង?

ខ៖ អត់ចេះទេ។

ក៖ បាទ! ហើយអញ្ជឹងច្រៀងនិងរាំអត់ចេះទេ។

ខ៖ បាទ! បើរាំមានលេងនិងគេខ្លះណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយបើច្រៀងនិងអត់ទេ។

ក៖ បាទ! បើច្រៀងអត់ទេកុង។

ខ៖ បាទ!

ក៖ បាទ!

ខ៖ បាទ! ហើយស្រីប៉ុនៗគ្នានិងមករោមតែខ្ញុំអត់ប៉ះពាលទេ។

ក៖ បាទ!

ខ៖ បាទ!
ព្រោះអីខ្ញុំខ្លាចជំនាន់និងខ្ញុំខ្លាចគេថាក្មេងៗនិងបើហ៊ានប៉ះពាល់ស្រីអីនិងប្រយ័ត្តគេចាប់ដាក់គុកអីនិងណាស់ហើយខ្ញុំខ្លាចខ្ញុំអត់ប៉ះពាលទេ។

ក៖ បាទ! អត់ប៉ះទេកុងណោះ។

ខ៖ បាទ! អត់ប៉ះទេ។

ក៖ បាទ! ហើយអញ្ជឹងបានប្រាប់ខ្ញុំថាប្អូនថ្លៃកុងចេះលេងភ្លេង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ជឹងចេះលេងអីដែរកុងដូចជាលេងស្គរ ហ្គីតា។

ខ៖ អរវាលេងតាខេយើងនិង។

ក៖ បាទ! ហើយអញ្ជឹងគាត់លេងតាខេកុង។

ខ៖ បាទ! នឹងហើយ។

ក៖ ហើយអញ្ចឹងគាត់លេងទ្រនិងកុង។

ខ៖ បាទ! លេងទ្រលេងតាខេនិង។

ក៖ បាទ!

ខ៖ ហើយមានបុណ្យការខួបឯណាៗគេជូលទៅហើយ។

ក៖ បាទ!

ខ៖ ហើយគេជូលទៅបុកលាក់ហើយគេជូលទៅថ្មីមអីនិង។

ក៖ បាទ!

ខ៖ ហើយនៅឯណាវាទៅទាំងអស់និងវាចេះណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីលក្ខណៈផ្ទះដែរកុងនៅជាមួយឪពុកម្ដាយជំនាន់មុនមានលក្ខណៈយ៉ាងមិចដែរកុងដូចជាផ្ទះគ្បឿងឬផ្ទះស្បៅកុង?

ខ៖ បាទ! ផ្ទះគ្បឿង។

ក៖ ផ្ទះគ្បឿងកុងណោះ។

ខ៖ បាទ!

ក៖ បាទ! ដំបូលគ្បឿងហើយជញ្ជាំងអីគេដែរកុង?

ខ៖ ជញ្ជាំងក្ដា។

ក៖ បាទ! ជញ្ជាំងក្ដាហើយអញ្ចឹងរណាបអីគេដែរកុង?

ខ៖ រណាបអាស្សីយើងពីដើមនិង។

ក៖ បាទ! រណាបអាស្សីយើងនិង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងជើងសសរឈើអាធំៗកុង?

ខ៖ បាទ! ជើងសសរធំៗណាស់។

ក៖ បាទ! ហើយអញ្ជឹងកាំជណ្ដើរឈើ។

ខ៖ ឈើ។

ក៖ កាំជណ្ដើរឈើ។

ខ៖ បាទ! ជំនាន់និងគ្មានថ្មទេ។

ក៖ បាទ! ហើយអញ្ជឹងផ្ទះនិងលោកឪពុកកុងធ្វើផ្ទាល់ឬក៏គាត់ជួលគេកុង។

ខ៖ បាទ! វាអញ្ជេកជីតាខ្ញុំនិងគាត់ធ្វើហើយគាត់រៀបធ្វើ។

ក៖ បាទ! ហើយអញ្ជឹងគាត់ជួលគ្នាទៅកុង។

ខ៖ បាទ! ហើយគាត់ជួយគ្នាទៅហើយជំនួងៗគាត់និងជំនួងគាត់និងទៅណាស់។

ក៖ បាទ! ហើយអញ្ជឹងជំនួងៗជួយគ្នាទៅកុង។

ខ៖ បាទៗ ជំនួងស្រីនិងជំនួងប្រុសជួយគ្នាទៅណាស់។

ក៖ បាទ! ហើយអញ្ជឹងគាត់អត់មានបានជួលគេទេកុង។

ខ៖ អត់ជួលទេអត់ទេជួលគេដែរតែជំនួងពីរនិងបង្ខំធ្វើផ្ទះអាងការកូន។

ក៖ បាទ! អញ្ជឹងទេ។

ខ៖ បាទ!

ក៖
ហើយអញ្ជឹងកុងបើនិយាយពីជំនាញវិញកុងអត់មានបន្តជំនាញពីឪពុកម្ដាយទេកុង?ហើយដូចជាកូរត្នោតហើយនិងត្បាញកន្ទេលក្រមាអីកុងទេចេះទេ?

ខ៖ បាទ! បើនិយាយពីដើមគាត់ចេះតែតើ។

ក៖ អត់ទេនិយាយពីកុងមានចេះទេ?

ខ៖ ខ្ញុំអត់ទេ។ហើយខ្ញុំទៅរៀនហើយពេលឪពុកស្លាប់ហើយខ្ញុំទៅ។

ក៖ មុះគ្រួសទៅកុង។

ខ៖ បាទ! ដូចថាមកមុះគ្រួសធ្វើអីអញ្ចឹងទៅណាស់។

ក៖ បាទ!

ខ៖ ហើយចិញ្ចឹមម្ដាយតទៅទៀតណាស់។

ក៖ បាទ!ៗ

ខ៖ ហើយជាមួយបងនិងទៅហើយចិញ្ចឹមម្ដាយទៅ។

ក៖ បាទ!

ខ៖ ហើយដល់ម្ដាយគាត់នេះទេកុំនិយាយអារឿងអាសភាសនោះ។

ក៖ បាទ!
អត់អីទេកុង។ហើយអញ្ចឹងកុងពេលដែរកុងបានចូលរៀនអញ្ចឹងកុងមានក្ដីស្រមៃថាពេលធំឡើងចង់ក្លាយជាគ្រូបង្រៀនហើយនិងគ្រូពេទ្យទាហាននិងប៉ូលិសទេកុង?

ខ៖ ខ្ញុំស្អីណាស់ខ្ញុំអត់ចូលចិត្តទេកាលណុង។

ក៖ បាទ! អត់ចូលចិត្តទេកុងណោះ។

ខ៖ បាទ! ព្រោះអីខ្ញុំក្លាយងាប់និង។

ក៖ បាទ! ខ្លាចងាប់អត់ចូលចិត្តធ្វើទាហានកុង?

ខ៖ បាទ!

ក៖ ហើយអញ្ចឹងកុងមានក្ដីស្រមៃចង់ធ្វើគ្រូនិងគ្រូពេទ្យអីនិងចូលចិត្តទេកុង?

ខ៖ ចេះតែមានហើយតែបុណ្យយើងទៅអត់ដល់ទេ។

ក៖ បាទ! ហើយណាមួយឪពុកយើងស្លាប់អញ្ចឹងណាស់។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងត្រូវការរកលុយចិញ្ចឹមម្ដាយអញ្ចឹងកុង?

ខ៖ បាទ! ត្រូវការរកលុយចិញ្ចឹមម្ដាយ។

កៈ បាទ! ហើយអញ្ចឹងកុងជាចុងក្រោយកុងមានពាក្យពេច៍ជាចុងក្រោយទៅកូនចៅជំនាន់ក្រោយឲ្យគាត់ខិតខំប្រឹងរៀនហើយនិងមានការតស៊ូនៅក្នុងជីវិតរបស់គាត់ទេកុង?

ខៈ បាទ! ហើយខ្ញុំគ្រាន់តែបង្ហាញផ្លូវវាដែរណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំប្រាប់ថាខ្ញុំពីដើមមកខ្ញុំមុះគ្រូសមុះអីនិងណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំទិញអំពៅលក់ទៅផ្សារតាយ៉េននិងរាល់ឆ្នាំអញ្ចឹងណាស់។

កៈ បាទ!

ខៈ ហើយបើខែនិងមុះគ្រូសហើយ។

កៈ បាទ! ហើយអញ្ចឹងកុងប្រាប់គាត់ថាចង់ឲ្យគាត់និងខិតខំប្រឹងរៀនទៅកុងណោះ។

ខៈ បាទ! ឲ្យខិតខំប្រឹងរៀនទៅណាស់។

កៈ បាទ!

ខៈ ហើយកូនចៅនិងវាខំប្រឹងរៀនទៅហើយវាខិតខំប្រឹងរៀនទៅមានការងារល្អធ្វើណាស់។

កៈ បាទ!

ខៈ ហើយឲ្យមានការងារអីជួយចិញ្ចឹមយើងតទៅមុខទៀតណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំគ្រាន់តែប្រដៅអញ្ចឹងទេហើយបើគាត់ធ្វើតាមក៏តាមទៅហើយបើគេអត់តាមយើងទៅហើយយើងអត់ដឹងធ្វើមិចដែរណាស់។

កៈ បាទ! ហើយអញ្ចឹងបើនិយាយពីគ្រឿងញៀនវិញកុងចង់ផ្តែផ្តាំឲ្យកូនចៅជំនាន់ក្រោយនិងឲ្យគាត់ជៀសវាងនិងគ្រឿងញៀនទេកុង?

ខៈ ហើយនិងខ្ញុំស្អប់ណាស់ខ្ញុំអត់ចូលចិត្តទេហើយខ្ញុំហាមអញ្ចឹងម៉ងណាស់។

កៈ បាទ! កុំជក់គ្រឿងញៀនហើយកុំដើរតាមមនុស្សមិនល្អ។

ខៈ បាទ! ហើយកុំសេពគប់និងមិត្តភក្តិអត់ល្អអញ្ចឹងណាស់។

កៈ បាទ!

ខៈ បាទ! ហើយមិត្តភក្តិណាល្អចាំតាមហើយមិត្តភក្តិណាអត់ល្អកុំតាម។

កៈ បាទ!

ខៈ ហើយយើងត្រូវដកខ្លួនយើងនិងបន្តជីវិតតទៅទៀត។

កៈ បាទ!

ខៈ ហើយយើងដើរតាមមនុស្សមិនល្អនាំយើងទៅរកផ្លូវវិនាស។

កៈ បាទ! ហើយអញ្ចឹងកុងមានពាក្យអីជាចុងក្រោយទេកុង?

ខៈ បាទ!

កៈ បាទ! អត់មានទេកុង។

ខៈ បាទ! អត់មានអីមានតែផ្តាំផ្ញើរប្អូននិងណាស់ទៅធ្វើការអីឲ្យបានសុខបានជម្រើន។

កៈ បាទ! អរគុណកុង។

ខៈ ហើយសូមទៅដល់អីណាសូមជូននិងព្រះពុទ្ធ ព្រះធម៌
ព្រះសង្ឃណាកុំបីឃ្លានឃ្លាតឡើយ។

កៈ បាទ!
អរគុណកុង។ហើយអញ្ចឹងជាចុងក្រោយខ្ញុំសូមអរគុណកុងដែរកុងបានញ៉ែកពេលវេលាដ៏មានតម្លៃមកកាន់សាលា BYU យើងខ្ញុំកុង។

ខៈ បាទ!

កៈ
ហើយអញ្ចឹងកុងអនុញ្ញាតឲ្យខ្ញុំយកសម្លេងរបស់កុងទៅឲ្យសាលាធ្វើការសិក្សានិងស្វែងយល់បានទេកុង?

ខៈ មានអីប្អូន។

កៈ បាទ!
អត់អីទេកុងហើយអញ្ជឹងខ្ញុំសូមអរគុណកុងសូមឲ្យកុងមានសុខភាពល្អហើយនិងមានអាយុវែងហើយជាម្លប់ដល់កូនចៅរបស់កុងអញ្ជឹងណាស់កុងហើយសូមឲ្យកុងជាគ្រប់ជម្ងឺណាកុងហើយសូមកូនចៅកុងគាត់កន្លងធម៌អញ្ជឹងកុង។

ខៈ បាទ!

កៈ ហើយអញ្ជឹងខ្ញុំសូមជំរាបលាកុង។